## ឧបសម្ព័ន្ធនៃពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពី ការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម

## បុព្វកថា

បណ្តាសមាជិក÷

អនុលោមតាមការចរចា ដែលបានធ្វើឡើងផ្អែកតាមសេចក្តីថ្លែងការណ៍រដ្ឋមន្ត្រីនៅទីក្រុងដូហា

បានឃើញនិងបានបញ្ជាក់អំពីអាណត្តិ និងគោលការណ៍ ដែលមានចែងក្នុងវាក្យខណ្ឌទី២៧ នៃសេចក្តីថ្លែងការណ៍រដ្ឋមន្ត្រីនៅទីក្រុងដូហា (WT/MIN(01)DEC/1) និងនៅក្នុងឧបសម្ព័ន្ធ ឃ នៃសេចក្តីសម្រេចស្តីពីកម្មវិធីការងារដូហាដែលបានអនុម័តដោយអគ្គក្រុមប្រឹក្សានៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៤(WT/L/579) ក៏ដូចជានៅក្នុងវាក្យខណ្ឌទី៣៣ និងឧបសម្ព័ន្ធ ង នៃសេចក្តីថ្លែងការណ៍រដ្ឋមន្ត្រីនៅទីក្រុងហុងកុង(WT/MIN (05)/DEC)

ដោយមានបំណងបញ្ជាក់ឱ្យច្បាស់ និងកែលម្អនូវទិដ្ឋភាពនានានៃមាត្រា៥ ៨ និង១០នៃកិច្ចព្រមព្រៀងទូទៅស្តីពីគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤ ក្នុងទស្សនៈធ្វើការពន្លឿននូវចរាចរណ៍ទំនិញ ការអនុញ្ញាតឱ្យយកទំនិញចេញនិងការបញ្ចេញទំនិញ រួមទាំងទំនិញឆ្លងកាត់

ដោយមើលឃើញនូវតម្រូវការដោយឡែករបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច និងដោយមានបំណងលើកកម្ពស់លើការផ្តល់ជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាពនៅក្នុងវិស័យនេះ

ដោយទទួលស្គាល់នូវតម្រូវការសម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងចំណោមសមាជិកស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម និងអនុលោមភាពគយ

ព្រមព្រៀងគ្នាដូចតទៅ÷

## ផ្នែកទី១

## មាត្រា ១÷ ការបោះពុម្ពផ្សាយនិងព័ត៌មានដែលអាចរកបាន

### ១. ការបោះពុម្ពផ្សាយ

១.១ សមាជិកនីមួយៗត្រូវបោះពុម្ពផ្សាយជាបន្ទាន់ក្នុងលក្ខណៈមិនរើសអើង និងងាយស្រួលរក ដើម្បីអនុញ្ញាតឱ្យរដ្ឋាភិបាល ធុរជន និងភាគីពាក់ព័ន្ធផ្សេងទៀត បានជ្រួតជ្រាបនូវព័ត៌មានដូចខាងក្រោម÷

(ក) នីតិវិធីនាំចូល នាំចេញ និងឆ្លងកាត់ (រួមទាំង នីតិវិធីនៅតាមកំពង់ផែ អាកាសយានដ្ឋាន និងនៅតាមមាត់ច្រកចូលផ្សេងទៀត) និងទម្រង់បែបបទ និងឯកសារតាមការតម្រូវផ្សេងៗ

(ខ) អត្រាពន្ធ និងអាករ ដែលបានដាក់ឱ្យអនុវត្តលើ ឬពាក់ព័ន្ធនឹងការនាំចូល និងការនាំចេញ

(គ) កម្រៃ និងបន្ទុកផ្សេងៗដែលបានដាក់ដោយ ឬសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលទៅលើ ឬពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ឬការឆ្លងកាត់

(ឃ) វិធានសម្រាប់ចំណាត់ថ្នាក់ទំនិញ ឬការកំណត់តម្លៃទំនិញក្នុងគោលបំណងគយ

(ង) ច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ

(ច) ការហាមឃាត់ និងការដាក់កម្រិតកំណត់លើការនាំចូល ការនាំចេញ ឬការឆ្លងកាត់

(ឆ) ទោសបទប្បញ្ញត្តិលើការរំលោភបំពានបែបបទនៃការនាំចូល ការនាំចេញ ឬការឆ្លងកាត់

(ជ) នីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ ឬការត្រួតពិនិត្យឡើងវិញ

(ឈ) កិច្ចព្រមព្រៀង ឬផ្នែកណាមួយនៃកិច្ចព្រមព្រៀងនោះ ធ្វើឡើងជាមួយប្រទេស ឬបណ្តាប្រទេសពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ឬការឆ្លងកាត់ និង

(ញ) នីតិវិធីពាក់ព័ន្ធនឹងការគ្រប់គ្រងកូតាពន្ធ

១.២ ពុំមានអ្វីនៅក្នុងបញ្ញត្តិនេះ ដែលត្រូវបកស្រាយថាបានតម្រូវឱ្យសមាជិកបោះពុម្ពផ្សាយ ឬផ្តល់ព័ត៌មានជាភាសាផ្សេងក្រៅពីភាសារបស់សមាជិកនោះឡើយ លើកលែងតែអ្វីដែលចែងក្នុងវាក្យខណ្ឌទី២.២។

## ២. ព័ត៌មានដែលអាចរកបានតាមរយៈអ៊ីនធើណេត

២.១ សមាជិកនីមួយៗត្រូវបង្កើត និងធ្វើបច្ចុប្បន្នភាពលើអ៊ីនធើណេតតាមដែលអាចធ្វើទៅបាន និងធ្វើឱ្យបានសមស្របនូវព័ត៌មានដូចខាងក្រោម÷

(ក) ការបរិយាយ[១] ស្តីពីនីតិវិធីប្រទេសសមាជិកសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ រួមទាំងនីតិវីធីបណ្តឹងឧទ្ធរណ៍ ឬការត្រួតពិនិត្យឡើងវិញ ដែលជាការជូនដំណឹងដល់រដ្ឋាភិបាលនៃសមាជិកនានា ធុរជន និងភាគីពាក់ព័ន្ធឱ្យបានដឹងពីនីតិវិធីអនុវត្តជាក់ស្តែងសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់

(ខ) ទម្រង់បែបបទ និងឯកសារនានា ដែលជាការតម្រូវសម្រាប់ការនាំចូល ការនាំចេញ និងការដឹកទំនិញឆ្លងកាត់ដែនដីរបស់សមាជិកនេះ

(គ) ព័ត៌មានសម្រាប់ការទំនាក់ទំនងអំពីកន្លែងសាកសួរព័ត៌មានរបស់សមាជិកនោះ។

២.២ បើអាចធ្វើទៅបាន ការបរិយាយដែលមានចែងនៅក្នុងវាក្យខណ្ឌ ២.១ (ក) ត្រូវធ្វើការផ្សព្វផ្សាយជាភាសាមួយក្នុងចំណោមភាសាផ្លូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក។

[១] សមាជិកនីមួយៗមានឆន្ទានុសិទ្ធិក្នុងការបញ្ជាក់លើគេហទំព័ររបស់ខ្លួនអំពីភាពមានកម្រិតខាងផ្លូវច្បាប់នៃការបរិយាយនេះ។

២.៣ សមាជិកត្រូវបានលើកទឹកចិត្តឱ្យបោះពុម្ពផ្សាយព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មបន្ថែមទៀតតាមរយៈអ៊ីធើណេតដូចជា បទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងប្រភេទព័ត៌មានផ្សេងទៀតដែលចែងក្នុងវាក្យខណ្ឌទី១.១។

## ៣. កន្លែងសាកសួរព័ត៌មាន

៣.១ សមាជិកនីមួយៗត្រូវបង្កើត ឬរក្សាទុកកន្លែងសាកសួរព័ត៌មានមួយ ឬច្រើនតាមធនធានដែលមានដើម្បីឆ្លើយតបទៅនឹងចម្ងល់ផ្សេងៗរបស់រដ្ឋាភិបាល ធុរជន និងភាគីពាក់ព័ន្ធផ្សេងៗ អំពីព័ត៌មានដែលមានចែងក្នុងវាក្យខណ្ឌទី១.១ និងដើម្បីផ្ដល់នូវព័ត៌ទម្រង់បែបបទនិងឯកសារនានាតាមការតម្រូវ ដូចមានចែងតាមវាក្យខណ្ឌ១.១(ក)។

៣.២ សមាជិកនៃសហភាពគយ សមាជិកដែលចូលរួមក្នុងសមាហរណកម្មតំបន់ ត្រូវបង្កើត ឬរក្សាទុកកន្លែងសាកសួរព័ត៌មានរួមនៅថ្នាក់តំបន់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងវាក្យខណ្ឌទី៣.១ ចំពោះនីតិវិធីរួមគ្នា។

៣.៣ សមាជិកត្រូវបានលើកទឹកចិត្តមិនឱ្យយកកម្រៃពីការឆ្លើយតបនឹងការសាកសួរព័ត៌មាន និងការផ្ដល់ទម្រង់បែបបទ និងឯកសារតាមការតម្រូវឡើយ។ ក្នុងករណីមានការគិតកម្រៃ សមាជិកត្រូវយកកម្រៃប្រហាក់ប្រហែលនឹងចំណាយសម្រាប់សេវាដែលបានផ្ដល់ជូនប៉ុណ្ណោះ។

៣.៤ កន្លែងសាកសួរព័ត៌មានត្រូវឆ្លើយតបនឹងសំណួរ និងផ្ដល់ទម្រង់បែបបទនិងឯកសារក្នុងរយៈពេលសមស្របតាមការកំណត់របស់សមាជិកនីមួយៗ ហើយរយៈពេលនេះអាចខុសគ្នាអាស្រ័យលើសារជាតិ និងភាពស្មុគស្មាញនៃសំណួរ។

## ៤. ការផ្ដល់ព័ត៌មាន

សមាជិកនីមួយៗ ត្រូវផ្ដល់ព័ត៌មានទៅគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្មដែលបានបង្កើតឡើងក្រោមវាក្យខណ្ឌទី១.១ នៃមាត្រា២៣ (ហៅកាត់ក្នុងកិច្ចព្រមព្រៀងស្ដីពីកិច្ចសម្រួលពាណិជ្ជកម្មនេះថា “គណៈកម្មាធិការ”) នូវ៖

(ក) ទីកន្លែងផ្លូវការដែលព័ត៌មាននានាក្នុងវាក្យខណ្ឌ១.១ (ក) ដល់ (ឍ) ត្រូវបានបោះពុម្ពផ្សាយ

(ខ) ទីតាំងគេហទំព័រដែលមានចែងក្នុងវាក្យខណ្ឌទី២.១ និង

(គ) ព័ត៌មានសម្រាប់ទំនាក់ទំនងនៃកន្លែងសាកសួរព័ត៌មាន ដែលមានចែងក្នុងវាក្យខណ្ឌទី៣.១។

## មាត្រា២÷ ឱកាសសម្រាប់បញ្ចេញយោបល់ ព័ត៌មានមុនពេលចូលជាធរមាន និងការពិគ្រោះយោបល់

**១. ឱកាសបញ្ចេញយោបល់និងព័ត៌មានមុនពេលចូលជាធរមាន**

១.១ ក្នុងលក្ខខណ្ឌមួយដែលអាចអនុវត្តបាន និងស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន សមាជិកនីមួយៗត្រូវផ្តល់ឱកាស និងពេលវេលាសមស្របដើម្បីឱ្យធុរជន និងភាគីពាក់ព័ន្ធនានាធ្វើការបញ្ចេញយោបល់លើសេចក្តីព្រាងច្បាប់ថ្មី និងបទប្បញ្ញត្តិ ឬសេចក្តីព្រាងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងការធ្វើចរាចរណ៍ទំនិញ ការអនុញ្ញាតឱ្យយកទំនិញចេញ និងការបញ្ចេញទំនិញរួមទាំងការឆ្លងកាត់។

១.២ ក្នុងលក្ខណៈមួយដែលអាចអនុវត្តបាន និងស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក សមាជិកនីមួយៗត្រូវធានាថាច្បាប់ និងបទប្បញ្ញត្តិថ្មី ឬវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងពាក់ព័ន្ធនឹងការធ្វើចរាចរណ៍ទំនិញ ការអនុញ្ញាតឱ្យយកទំនិញចេញនិងការបញ្ចេញទំនិញ រួមទាំងការឆ្លងកាត់ ត្រូវចុះផ្សាយ ឬព័ត៌មានទាំងនោះត្រូវដាក់ឱ្យអាចរកបានជាសាធារណៈ ឱ្យបានឆាប់តាមការដែលអាចធ្វើទៅបានមុនពេលច្បាប់ និងបទប្បញ្ញត្តិទាំងនោះចូលជាធរមាន ដើម្បីឱ្យធុរជន និងភាគីពាក់ព័ន្ធនានាបានដឹង។

១.៣ ការកែប្រែអត្រាពន្ធអាករ និងវិធានការនានាដែលនាំឱ្យមានភាពធូរស្រាលជាងមុន វិធានការនានាដែលបន្ធូរបន្ថយ ជាលទ្ធផលនៃការតវ៉ាស្របតាម វាក្យខណ្ឌទី១.១ ឬទី១.២, វិធានការសម្រាប់អនុវត្តក្នុងកាលៈទេសៈបន្ទាន់ ឬការកែសម្រួលតិចតួចចំពោះច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក និងប្រព័ន្ធច្បាប់មិនចាំបាច់អនុវត្តតាមវាក្យខណ្ឌទី១.១ និងទី១.២ ឡើយ។

**២. ការពិគ្រោះយោបល់**

សមាជិកនីមួយៗ ត្រូវផ្តល់ឱ្យមានការពិគ្រោះយោបល់សមស្របជាប្រចាំរវាងស្ថាប័នព្រំដែន និងធុរជន ឬភាគីពាក់ព័ន្ធនានាដែលស្ថិតនៅក្នុងដែនដីរបស់សមាជិកនោះ។

## មាត្រា ៣÷វិធានបញ្ជាក់ជាមុន

**១.** សមាជិកនីមួយៗ ត្រូវចេញវិធានបញ្ជាក់ជាមុនក្នុងលក្ខណៈមួយសមស្រប និងមានពេលវេលាកំណត់ជូនដល់អ្នកដាក់ពាក្យសុំ ដែលបានដាក់ជូននូវសំណើជាលាយលក្ខណ៍អក្សរជាមួយនឹងព័ត៌មានចាំបាច់ទាំងអស់។ ប្រសិនបើ សមាជិកបដិសេធមិនចេញវិធានបញ្ជាក់ជាមុន សមាជិកនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់អ្នកដាក់ពាក្យសុំ ដោយបញ្ជាក់អំពីអង្គហេតុនិងមូលដ្ឋាននានាសម្រាប់សេចក្តីសម្រេចនោះ។

**២.** សមាជិកអាចបដិសេធមិនចេញវិធានបញ្ជាក់ជាមុនជូនដល់អ្នកដាក់ពាក្យសុំ នៅពេលដែលការស្នើសុំនោះ÷

(ក) ត្រូវបានព្យួរទុករួច ដោយទីភ្នាក់ងាររដ្ឋាភិបាល សាលាឧទ្ធរណ៍ ឬតុលាការ ឬ

(ខ) ត្រូវបានសម្រេចរួចហើយដោយសាលាឧទ្ធរណ៍ ឬតុលាការណាមួយ

៣. វិធានបញ្ជាក់ជាមុន ត្រូវមានសុពលភាពសម្រាប់រយៈពេលមួយសមស្រប គិតចាប់ពីពេលចេញឱ្យ លើកលែងតែច្បាប់ អង្គហេតុ ឬកាលៈទេសៈណាមួយដែលគាំទ្រវិធាននោះមានការកែប្រែ។

៤. ក្នុងករណីដែលសមាជិកសម្រេចលុបចោល កែសម្រួល ឬបញ្ចប់សុពលភាពវិធានបញ្ជាក់ជាមុន សមាជិកនោះ ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យសុំដោយបញ្ជាក់អំពីអង្គហេតុ និងមូលដ្ឋានពាក់ព័ន្ធនឹងការសម្រេចនោះ។ សមាជិកអាចធ្វើការសម្រេចលុបចោល កែសម្រួល ឬបញ្ចប់សុពលភាពវិធានបញ្ជាក់ជាមុនក្នុងលក្ខណៈប្រតិសកម្ម សមាជិកនោះអាចធ្វើដូច្នេះបានតែក្នុងលក្ខខណ្ឌដែលវិធានបញ្ជាក់ជាមុននោះ ត្រូវបានចេញដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ក្លែងក្លាយ ឬព័ត៌មានដែលបង្កឱ្យមានការយល់ច្រឡំ។

៥. វិធានបញ្ជាក់ជាមុនដែលចេញដោយសមាជិក ត្រូវចងកាតព្វកិច្ចចំពោះសមាជិកនោះដែលមានការពាក់ព័ន្ធជាមួយនឹងអ្នកដាក់ពាក្យសុំដែលស្នើសុំវិធានបញ្ជាក់ជាមុន។ សមាជិកអាចកំណត់ថា វិធានបញ្ជាក់ជាមុនគឺជាកាតព្វកិច្ចចំពោះអ្នកដាក់ពាក្យសុំ។

៦. សមាជិកនីមួយៗត្រូវចុះផ្សាយ យ៉ាងហោចណាស់នូវ៖

(ក) លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំវិធានបញ្ជាក់ជាមុន រួមទាំងព័ត៌មានដែលត្រូវបំពេញនិងទម្រង់

(ខ) រយៈពេលសម្រាប់ការចេញវិធានបញ្ជាក់ជាមុន

(គ) រយៈពេលសុពលភាពនៃវិធានបញ្ជាក់ជាមុន

៧. តាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សររបស់អ្នកដាក់ពាក្យសុំ សមាជិកនីមួយៗត្រូវផ្តល់ឱ្យមានការពិនិត្យឡើងវិញលើវិធានបញ្ជាក់ជាមុន ឬសេចក្តីសម្រេចលុបចោល កែសម្រួល ឬបញ្ចប់សុពលភាពនៃវិធានបញ្ជាក់ជាមុន[២]។

៨. សមាជិកនីមួយៗ ត្រូវខិតខំដាក់រាល់ព័ត៌មានពាក់ព័ន្ធនឹងវិធានបញ្ជាក់ជាមុនឱ្យអាចរកបានជាសាធារណៈដែលសមាជិកនោះយល់ឃើញថាមានផលប្រយោជន៍ច្រើនចំពោះភាគីពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីតម្រូវការនៃការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម។

### ៩. និយមន័យ និងវិសាលភាព

(ក) វិធានបញ្ជាក់ជាមុនគឺជាសេចក្តីសម្រេចលាយលក្ខណ៍អក្សរដែលផ្តល់ជូនអ្នកដាក់ពាក្យសុំដោយសមាជិកនៅមុនពេលនាំទំនិញចូលដោយអ្នកដាក់ពាក្យសុំ ដោយកំណត់ជាមុននូវប្រព្រឹត្តកម្មដែលសមាជិកត្រូវផ្តល់ចំពោះទំនិញនោះ នៅពេលធ្វើការនាំចូលទំនិញ ពាក់ព័ន្ធនឹង៖

---

[២] នៅក្នុងវាក្យខណ្ឌ៖ (ក) ទោះបីមុន ឬក្រោយពេលអនុវត្តវិធានបញ្ជាក់ជាមុនក៏ដោយ ការត្រួតពិនិត្យឡើងវិញត្រូវធ្វើឡើងដោយមន្ត្រី ដោយការិយាល័យ ឬដោយអាជ្ញាធរដែលចេញវិធានបញ្ជាក់ជាមុន អាជ្ញាធររដ្ឋបាលដែលមានឋានានុក្រមខ្ពស់ជាង ឬអាជ្ញាធររដ្ឋបាលឯករាជ្យ ឬស្ថាប័នតុលាការ និង (ខ) សមាជិកមិនត្រូវបានតម្រូវឱ្យផ្តល់ដល់អ្នកដាក់ពាក្យសុំជាមួយនឹងការប្រើប្រាស់វាក្យខណ្ឌទី១ នៃមាត្រា៤ ឡើយ។

(i) ចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ និង

(ii) ដើមកំណើតទំនិញ[៣]

(ខ) បន្ថែមពីលើវិធានបញ្ជាក់ជាមុនដែលបានកំណត់ក្នុងវាក្យខណ្ឌ (ក) សមាជិកត្រូវបានលើកទឹកចិត្តផងដែរ ក្នុងការផ្តល់វិធានបញ្ជាក់ជាមុនពាក់ព័ន្ធនឹង÷

(i) វិធីសាស្ត្រ ឬលក្ខណៈវិនិច្ឆ័យសមស្រប និងការប្រើប្រាស់វិធីសាស្ត្រ ឬលក្ខណៈវិនិច្ឆ័យទាំងនោះ ដែលត្រូវប្រើសម្រាប់កំណត់តម្លៃពន្ធគយផ្អែកលើបណ្តុំអង្គហេតុជាក់លាក់

(ii) លក្ខខណ្ឌតម្រូវរបស់សមាជិក ដែលអាចអនុវត្តបានសម្រាប់កាត់បន្ថយ ឬលើកលែងពន្ធគយ

(iii) លក្ខខណ្ឌតម្រូវរបស់សមាជិក ដែលអាចអនុវត្តសម្រាប់ការផ្តល់កូតា រួមទាំងកូតាពន្ធគយ និង

(iv) កិច្ចការផ្សេងៗទៀតដែលសមាជិកយល់ឃើញថា ជាការសមស្របក្នុងការចេញវិធានបញ្ជាក់ជាមុន

(គ) អ្នកដាក់ពាក្យសុំ គឺជាអ្នកនាំចេញ អ្នកនាំចូល ឬជាបុគ្គលដែលមានលក្ខណៈសមស្របក្នុងការដាក់ពាក្យសុំ ឬជាអ្នកតំណាងនៃអ្នកទាំងនោះ។

(ឃ) សមាជិកអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំមានតំណាងស្របច្បាប់ ឬចុះបញ្ជីស្របច្បាប់នៅក្នុងដែនដីរបស់ខ្លួន។ ប្រសិនបើអាច លក្ខខណ្ឌនេះមិនត្រូវរឹតត្បិតប្រភេទនៃបុគ្គលដែលមានសិទ្ធិស្នើសុំវិធានបញ្ជាក់ជាមុនឡើយ ជាមួយនឹងការគិតគូរជាពិសេសចំពោះសេចក្តីត្រូវការជាក់លាក់របស់សហគ្រាសធុនតូច និងមធ្យម។ លក្ខខណ្ឌតម្រូវទាំងនេះ ត្រូវមានភាពច្បាស់លាស់ និងមានតម្លាភាព ដោយមិនត្រូវបង្កឱ្យមានការរើសអើងដោយបំពាន ឬមិនសមស្រប។

## មាត្រា ៤÷ នីតិវិធីបណ្តឹងឧទ្ធរណ៍ ឬត្រួតពិនិត្យឡើងវិញ

**១.** សមាជិកនីមួយៗ ត្រូវកំណត់ថាបុគ្គលដែលទទួលបានសេចក្តីសម្រេចរដ្ឋបាល[៤] ពីគយ នៅក្នុងដែនដីរបស់ខ្លួន

---

[៣] មានការយល់ឃើញថា វិធានបញ្ជាក់ជាមុនអំពីដើមកំណើតទំនិញ អាចជាការវាយតម្លៃអំពីដើមកំណើតទំនិញសម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងស្តីពីវិធានដើមកំណើតទំនិញ នៅពេលដែលវិធានបំពេញបានតាមលក្ខខណ្ឌតម្រូវនានានៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងស្តីពីវិធានដើមកំណើតទំនិញ។ ដូចគ្នានេះដែរ ការវាយតម្លៃអំពីដើមកំណើតទំនិញដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីវិធានដើមកំណើតទំនិញ អាចជាវិធានបញ្ជាក់ជាមុនអំពីដើមកំណើតទំនិញសម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះនៅពេលដែលវិធាននេះបំពេញបានតាមលក្ខខណ្ឌតម្រូវនានានៃកិច្ចព្រមព្រៀងទាំងពីរ។ សមាជិកនានា មិនតម្រូវឱ្យបង្កើតយន្តការពីរដាច់ដោយឡែកពីគ្នានៅក្រោមបញ្ញត្តិនេះ បន្ថែមពីលើអ្វីដែលត្រូវបានបង្កើតឡើងផ្អែកតាមកិច្ចព្រមព្រៀងស្តីពីវិធានដើមកំណើតទំនិញ ពាក់ព័ន្ធនឹងការវាយតម្លៃដើមកំណើតទំនិញឡើយ ប្រសិនបើលក្ខខណ្ឌនានានៃមាត្រានេះត្រូវបានបំពេញរួចរាល់។

[៤] សេចក្តីសម្រេចរដ្ឋបាលក្នុងមាត្រានេះ មានន័យថា ជាសេចក្តីសម្រេចដែលមានអានុភាពគតិយុត្តិលើសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលជាក់លាក់ណាមួយនៅក្នុងករណីនីមួយៗ។ សូមយល់ថា សេចក្តីសម្រេចរដ្ឋបាលក្នុងមាត្រានេះមានវិសាលភាពគ្របដណ្តប់លើវិធានការរដ្ឋបាលក្នុងនិយមន័យនៃមាត្រា១០នៃកិច្ចព្រមព្រៀងស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ (GATT 1994) ឬការខកខានក្នុងការចាត់វិធានការ ឬធ្វើសេចក្តីសម្រេចរដ្ឋបាលដូចដែលមានចែងក្នុងច្បាប់ក្នុងស្រុក និងប្រព័ន្ធច្បាប់របស់សមាជិក។ ដើម្បីដោះស្រាយបញ្ហាខកខាននេះ សមាជិកអាចប្រើប្រាស់យន្តការរដ្ឋបាលផ្សេង ឬប្រព័ន្ធតុលាការ ដើម្បីណែនាំដល់អាជ្ញាធរគយឱ្យចេញសេចក្តីសម្រេចរដ្ឋបាលជាបន្ទាន់ស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ឬការត្រួតពិនិត្យឡើងវិញ នៅក្រោមវាក្យខណ្ឌ១ (ក)។

មានសិទ្ធិ÷

(ក) ធ្វើបណ្តឹងរដ្ឋបាល ឬបណ្តឹងឱ្យត្រួតពិនិត្យឡើងវិញទៅអាជ្ញាធររដ្ឋបាលដែលខ្ពស់ជាង ឬអាជ្ញាធរដែលមានឯករាជ្យភាពដាច់ពីមន្ត្រី ឬការិយាល័យដែលចេញសេចក្តីសម្រេចនោះ

(ខ) ធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការ ឬបណ្តឹងឱ្យត្រួតពិនិត្យឡើងវិញលើសេចក្តីសម្រេចនោះ

**២.** បទប្បញ្ញត្តិរបស់សមាជិកអាចតម្រូវឱ្យមានបណ្តឹងរដ្ឋបាល ឬបណ្តឹងឱ្យត្រួតពិនិត្យឡើងវិញ មុននឹងដាក់បណ្តឹងឧទ្ធរណ៍ ឬការត្រួតពិនិត្យឡើងវិញទៅតុលាការ។

**៣.** សមាជិកនីមួយៗត្រូវធានាថានីតិវិធីបណ្តឹងឧទ្ធរណ៍ ឬត្រួតពិនិត្យឡើងវិញរបស់ខ្លួនត្រូវធ្វើឡើងក្នុងលក្ខណៈមិនរើសអើង។

**៤.** សមាជិកត្រូវធានាថា ប្រសិនបើសេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍ ឬការត្រួតពិនិត្យឡើងវិញក្នុងវាក្យខណ្ឌ១(ក) មិនត្រូវបានធ្វើឡើង÷

(ក) ក្នុងរយៈពេលដែលកំណត់ក្នុងច្បាប់ ឬបទប្បញ្ញត្តិរបស់ខ្លួន ឬ

(ខ) ដោយមិនពន្យារពេលហួសហេតុ

អ្នកដាក់ញត្តិតវ៉ា មានសិទ្ធិបន្តប្តឹងឧទ្ធរណ៍ ឬបន្តប្តឹងឱ្យត្រួតពិនិត្យឡើងវិញទៅអាជ្ញាធររដ្ឋបាល ឬអាជ្ញាធរតុលាការ ឬអាចប្រើប្រាស់មធ្យោបាយផ្សេងទៀត ប្តឹងទៅអាជ្ញាធរតុលាការ[៥]។

**៥.** សមាជិកនីមួយៗ ត្រូវធានាថាបុគ្គលដែលបាននិយាយសំដៅដល់ក្នុងវាក្យខណ្ឌទី១ ទទួលបានព័ត៌មានអំពីមូលហេតុនៃសេចក្តីសម្រេចរដ្ឋបាលនោះ ដើម្បីបុគ្គលនោះអាចប្រើប្រាស់នីតិវិធីនានាដើម្បីប្តឹងឧទ្ធរណ៍ ឬប្តឹងឱ្យត្រួតពិនិត្យឡើងវិញ ប្រសិនបើចាំបាច់។

**៦.** សមាជិកនីមួយៗ ត្រូវលើកទឹកចិត្តឱ្យអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះទៅលើសេចក្តីសម្រេចរដ្ឋបាលចេញដោយទីភ្នាក់ងារព្រំដែនពាក់ព័ន្ធផ្សេងទៀតក្រៅពីគយ។

## មាត្រា ៥÷ វិធានការដទៃទៀតដើម្បីធ្វើឱ្យប្រសើរឡើង នូវភាពមិនលំអៀង ភាពមិនរើសអើង និងតម្លាភាព

### ១. ការផ្តល់ព័ត៌មានអំពីការធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ ឬអធិការកិច្ច

នៅពេលដែលសមាជិកបានអនុម័ត ឬរក្សានូវប្រព័ន្ធនៃការចេញសេចក្តីជូនដំណឹង ឬសេចក្តីណែនាំដល់អាជ្ញាធរពាក់ព័ន្ធនានារបស់ខ្លួនអំពីការធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ ឬអធិការកិច្ចតាមព្រំដែនចំពោះផលិតផលម្ហូបអាហារ ភេសជ្ជៈ ឬចំណីអាហារទូទៅដែលស្ថិតក្រោមវិសាលភាពនៃការជូនដំណឹង ឬសេចក្តី

---

[៥] គ្មានអ្វីនៅក្នុងបទប្បញ្ញត្តិនេះ ដែលរារាំងដល់សមាជិកនានាមិនឱ្យទទួលស្គាល់នូវសេចក្តីសម្រេចរដ្ឋបាល ដោយពុំមានបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឱ្យត្រួតពិនិត្យឡើងវិញ ជាសេចក្តីសម្រេចសម្រាប់តវ៉ាស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់សមាជិកនោះឡើយ។

ណែនាំក្នុងគោលបំណងការពារអាយុជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ក្នុងដែនដីរបស់ខ្លួន វិធានដូចខាងក្រោម ត្រូវយកមកអនុវត្តសម្រាប់ការចេញ ការបញ្ឈប់ ឬការផ្អាក÷

(ក) សមាជិកអាចចេញសេចក្តីជូនដំណឹង ឬសេចក្តីណែនាំនានា ផ្អែកលើហានិភ័យ

(ខ) សមាជិក អាចចេញសេចក្តីជូនដំណឹង ឬសេចក្តីណែនាំសម្រាប់អនុវត្តដូចគ្នាទាំងស្រុងសម្រាប់តែច្រកនាំចូលទាំងឡាយណាដែលលក្ខខណ្ឌអនាម័យ និងភូតគាមអនាម័យ គឺជាមូលដ្ឋាននៃការចេញសេចក្តីជូនដំណឹង និងសេចក្តីណែនាំប៉ុណ្ណោះ

(គ) សមាជិកត្រូវបញ្ឈប់ ឬផ្អាកជាបន្ទាន់នូវការចេញសេចក្តីជូនដំណឹង ឬសេចក្តីណែនាំនៅពេលណាដែលកាលៈទេសៈដែលនាំឱ្យមានការចេញសេចក្តីជូនដំណឹង ឬការណែនាំនោះលែងមានតទៅទៀត ឬប្រសិនបើ កាលៈទេសៈប្រែប្រួលអាចត្រូវបានដោះស្រាយ ក្នុងលក្ខណៈមួយដែលការរឹតត្បិតដល់ពាណិជ្ជកម្មមានភាពធូរស្រាលជាង និង

(ឃ) នៅពេលដែលមានសមាជិកសម្រេចបញ្ឈប់ ឬផ្អាកការចេញសេចក្តីជូនដំណឹង ឬសេចក្តីណែនាំ សមាជិកនោះ ត្រូវបោះផ្សាយជាបន្ទាន់នូវសេចក្តីប្រកាសព័ត៌មានអំពីការបញ្ឈប់ ឬការផ្អាកនោះ ក្នុងលក្ខណៈមិនរើសអើង និងងាយស្រួលស្វែងរកបាន ឬត្រូវការជូនដំណឹងដល់សមាជិកនាំចេញ ឬអ្នកនាំចូល។

## ២. ការឃាត់ទុក

សមាជិក ត្រូវជូនដំណឹងបន្ទាន់ដល់អ្នកដឹកជញ្ជូន ឬអ្នកនាំចូលក្នុងករណីដែលមានការឃាត់ទុកទំនិញដែលបានធ្វើប្រតិវេទន៍នាំចូល សម្រាប់ការធ្វើអធិការកិច្ចដោយគយ ឬដោយអាជ្ញាធរមានសមត្ថកិច្ចនានា។

## ៣. នីតិវិធីធ្វើតេស្ត

៣.១ ប្រសិនបើមានការស្នើសុំ សមាជិកអាចផ្តល់ឱកាសសម្រាប់ការធ្វើតេស្តជាលើកទីពីរ ក្នុងករណីលទ្ធផលនៃការធ្វើតេស្តលើកទីមួយទៅលើគំរូទំនិញដែលទើបមកដល់ នៃទំនិញដែលបានធ្វើប្រតិវេទន៍នាំចូលបង្ហាញនូវលទ្ធផលមិនល្អ។

៣.២ សមាជិកត្រូវបោះផ្សាយក្នុងលក្ខណៈមិនរើសអើង និងមានលក្ខណៈងាយស្រួលស្វែងរកបាននូវឈ្មោះនិងអាសយដ្ឋាននៃមន្ទីរពិសោធន៍ណាដែលអាចធ្វើតេស្តផលិតផល ឬផ្តល់ព័ត៌មាននេះទៅអ្នកនាំចូលនៅពេលដែលសមាជិកនោះផ្តល់នូវឱកាសធ្វើតេស្តដូចមានចែងក្នុងវាក្យខណ្ឌទី៣.១។

៣.៣ សមាជិកត្រូវធ្វើការពិចារណាទៅលើលទ្ធផលនៃការធ្វើតេស្តលើកទីពីរ ប្រសិនបើមាន ដែលតេស្តនោះត្រូវបានធ្វើឡើងក្រោមវាក្យខណ្ឌទី៣.១ សម្រាប់ការអនុញ្ញាតឱ្យយកទំនិញចេញនិងការបញ្ចេញទំនិញ និងប្រសិនបើសមស្រប គួរទទួលយកលទ្ធផលនៃការធ្វើតេស្តនោះ។

## មាត្រា ៦÷ វិន័យស្ដីពីការយកកម្រៃនិងបន្ទុក ឬ
## វិន័យពាក់ព័ន្ធនឹងការនាំចូលនិងការនាំចេញ និងទោសទណ្ឌ

### ១. វិន័យទូទៅស្ដីពីការយកកម្រៃនិងបន្ទុក ឬវិន័យពាក់ព័ន្ធនឹងការនាំចូលនិងការនាំចេញ

១.១ បញ្ញត្តិនានានៃវាក្យខណ្ឌទី១ ត្រូវអនុវត្តចំពោះការយកកម្រៃ និងបន្ទុកក្រៅពីពន្ធអាករនាំចូល និងនាំចេញ និងក្រៅពីពន្ធអាករ ដូចមានចែងក្នុងមាត្រា៣ នៃកិច្ចព្រមព្រៀងទូទៅស្ដីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ (GATT 1994) ដែលកំណត់ដោយសមាជិកទៅលើ ឬពាក់ព័ន្ធនឹងទំនិញនាំចូល នាំចេញ។

១.២ ព័ត៌មានស្ដីពីកម្រៃ និងបន្ទុក ត្រូវបោះពុម្ពផ្សាយដោយអនុលោមតាមមាត្រា១។ ព័ត៌មានដែលត្រូវផ្សព្វផ្សាយរួមមាន កម្រៃ និងបន្ទុកដែលត្រូវអនុវត្ត មូលហេតុនៃការយកកម្រៃនិងបន្ទុក អាជ្ញាធរទទួលបន្ទុក និងពេលវេលា និងវិធីសាស្ត្រនៃការទូទាត់។

១.៣ ត្រូវមានរយៈពេលមួយសមស្របនៅចន្លោះនៃការបោះពុម្ពផ្សាយកម្រៃ និងបន្ទុកថ្មី ឬដែលកែសម្រួល និងពេលចូលជាធរមាននៃការចាប់ផ្តើមយកកម្រៃ និងបន្ទុកថ្មី ឬកែសម្រួល លើកលែងតែនៅក្នុងកាលៈទេសៈបន្ទាន់។ កម្រៃ ឬបន្ទុកទាំងនេះ នឹងមិនត្រូវបានអនុវត្តឡើយ ប្រសិនបើព័ត៌មានស្ដីពីកម្រៃ ឬបន្ទុកទាំងនេះ មិនទាន់ត្រូវបានបោះពុម្ពផ្សាយនៅឡើយ។

១.៤ សមាជិកនីមួយៗ ត្រូវត្រួតពិនិត្យយ៉ាងទៀងទាត់នូវកម្រៃនិងបន្ទុករបស់ខ្លួន ក្នុងគោលបំណងកាត់បន្ថយចំនួន និងប្រភេទនៃកម្រៃនិងបន្ទុកទាំងនោះ ប្រសិនបើអាចធ្វើទៅបាន។

### ២. វិន័យជាក់លាក់ស្ដីពីកម្រៃ និងបន្ទុកដែលកំណត់សម្រាប់ដំណើរការនីតិវិធីគយ ឬពាក់ព័ន្ធនឹងការនាំចូល និងការនាំចេញ

កម្រៃនិងបន្ទុកសម្រាប់ដំណើរការនីតិវិធីគយ÷

(i) ត្រូវកម្រិតត្រឹមតម្លៃប្រហាក់ប្រហែលនឹងតម្លៃសេវាដែលបានផ្តល់ជូន ឬពាក់ព័ន្ធនឹងប្រតិបត្តិការនាំចូល ឬនាំចេញជាក់ស្ដែងនោះ និង

(ii) មិនតម្រូវឱ្យមានការផ្សារភ្ជាប់ទៅនឹងប្រតិបត្តិការនាំចូល ឬនាំចេញជាក់លាក់ណាមួយនោះទេ ប្រសិនបើកម្រៃនិងបន្ទុកនោះ ត្រូវបានយកសម្រាប់ទូទាត់សេវាកម្មដែលមានការពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងនីតិវិធីពិនិត្យទំនិញរបស់គយ។

### ៣. វិន័យស្ដីពីទោសទណ្ឌ

៣.១ នៅក្នុងគោលបំណងនៃវាក្យខណ្ឌទី៣ ពាក្យ “ទោសទណ្ឌ” សំដៅដល់ទោសទណ្ឌដែលដាក់ដោយអាជ្ញាធរគយរបស់សមាជិកចំពោះការបំពានច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវនៃនីតិវិធីគយរបស់សមាជិក។

៣.២ សមាជិកត្រូវធានាថា ការដាក់ទោសទណ្ឌចំពោះការបំពានច្បាប់ បទប្បញ្ញត្តិគយ និងលក្ខខណ្ឌតម្រូវ

នៃនីតិវិធីគយ ត្រូវធ្វើឡើងតែចំពោះបុគ្គលណាដែលទទួលខុសត្រូវចំពោះការបំពាននៅក្រោមច្បាប់របស់ខ្លួនប៉ុណ្ណោះ។

៣.៣ ការដាក់ទោសទណ្ឌ ត្រូវធ្វើឡើងដោយផ្អែកលើអង្គហេតុ និងកាលៈទេសៈនៃករណីហើយត្រូវប្រហាក់ប្រហែលនឹងកម្រិត និងភាពធ្ងន់ធ្ងរនៃការបំពាននោះ។

៣.៤ សមាជិកនីមួយៗ ត្រូវធានាថាខ្លួនមានវិធានការនានា ដើម្បីចៀសវាងនូវ÷

(ក) ទំនាស់ផលប្រយោជន៍ នៅក្នុងការវាយតម្លៃអំពីទោសទណ្ឌ និងការប្រមូលពន្ធគយ និង

(ខ) ការបង្កើតឱ្យមានការលើកទឹកចិត្តចំពោះការវាយតម្លៃ និងការប្រមូលពន្ធពីការដាក់ទោសទណ្ឌ ដែលផ្ទុយនឹងវាក្យខណ្ឌទី៣.៣។

៣.៥ សមាជិកនីមួយៗ ត្រូវធានាថា នៅពេលធ្វើការដាក់ទោសទណ្ឌចំពោះការបំពានច្បាប់ បទប្បញ្ញត្តិគយ និងលក្ខខណ្ឌតម្រូវនៃនីតិវិធីគយ សមាជិកត្រូវផ្តល់សេចក្តីពន្យល់ជាលាយលក្ខណ៍អក្សរដល់បុគ្គលដែលទទួលរងការដាក់ទោសទណ្ឌ ដោយត្រូវបញ្ជាក់អំពីសារជាតិបំពាន និងច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាន ដែលត្រូវយកមកប្រើជាមូលដ្ឋានសម្រាប់កំណត់ចំនួនទឹកប្រាក់ ឬទំហំនៃទោសទណ្ឌ។

៣.៦ ក្នុងករណីដែលបុគ្គលបំពានច្បាប់ បទប្បញ្ញត្តិគយ និងលក្ខខណ្ឌតម្រូវនៃនីតិវិធីគយ ស្ម័គ្រចិត្តសារភាពប្រាប់ដល់អាជ្ញាធរគយរបស់សមាជិកអំពីការបំពានច្បាប់ បទប្បញ្ញត្តិគយ និងលក្ខខណ្ឌតម្រូវនៃនីតិវិធីរបស់ខ្លួន មុនពេលអាជ្ញាធរគយរកឃើញការបំពាននោះ សមាជិកត្រូវបានលើកទឹកចិត្តឱ្យពិចារណាអំពីអង្គហេតុនេះ ដោយចាត់ទុកថាជាកត្តាមួយសម្រាប់បន្ធូរបន្ថយទោសនៅពេលដាក់ទោសទណ្ឌលើបុគ្គលនោះ ប្រសិនបើអាចធ្វើបាន។

៣.៧ បញ្ញត្តិនានានៃវាក្យខណ្ឌនេះ ត្រូវអនុវត្តចំពោះការដាក់ទោសទណ្ឌលើការធ្វើចរាចរទំនិញឆ្លងកាត់ដែលចែងក្នុងវាក្យខណ្ឌទី៣.១។

## មាត្រា ៧÷ ការអនុញ្ញាតឱ្យយកទំនិញចេញនិងការបញ្ចេញទំនិញ

### ១. នីតិវិធីមុនពេលទំនិញមកដល់

១.១ សមាជិកនីមួយៗត្រូវអនុម័ត ឬរក្សាទុកនីតិវិធីដែលអនុញ្ញាតឱ្យមានការផ្តល់ជាមុននូវឯកសារនាំចូល និងព័ត៌មានដែលតម្រូវផ្សេងៗទៀត រួមទាំងនិវេទបណ្ណដើម្បីចាប់ផ្តើមនីតិវិធីគយមុនពេលទំនិញមកដល់ ក្នុងគោលបំណងពន្លឿនការការអនុញ្ញាតឱ្យយកទំនិញចេញនៅពេលទំនិញមកដល់។

### ២. ការទូទាត់តាមប្រព័ន្ធអេឡិកត្រូនិក

តាមការដែលអាចអនុវត្តបាន សមាជិកនីមួយៗត្រូវអនុម័ត ឬរក្សាទុកនីតិវិធីដែលអនុញ្ញាតឱ្យមានការទូទាត់តាមប្រព័ន្ធអេឡិកត្រូនិកចំពោះពន្ធ អាករ កម្រៃ និងបន្ទុកផ្សេងទៀតដែលត្រូវប្រមូលដោយគយនៅពេលធ្វើការនាំចេញ និងនាំចូលទំនិញ។

## ៣. ការញែកពីគ្នារវាងការបញ្ចេញទំនិញ និងការកំណត់ចុងក្រោយនូវពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេង

៣.១ សមាជិកនីមួយៗត្រូវអនុម័ត ឬរក្សាទុកនីតិវិធីដែលអនុញ្ញាតឱ្យមានការបញ្ចេញទំនិញមុនពេលកំណត់ចុងក្រោយនូវពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេងៗ ប្រសិនបើការកំណត់នេះមិនបានធ្វើរួចរាល់នៅមុនពេលទំនិញមកដល់ ឬក្នុងពេលទំនិញមកដល់ ឬមិនអាចធ្វើបានលឿនតាមដែលអាចធ្វើទៅបានក្រោយពេលទំនិញមកដល់ ក្នុងករណីដែលលក្ខខណ្ឌតម្រូវខាងច្បាប់ត្រូវបានបំពេញរួចហើយ។

៣.២ ជាលក្ខខណ្ឌដើម្បីបញ្ចេញទំនិញបែបនេះ សមាជិកអាចតម្រូវឱ្យមាន÷

(ក) ការបង់ពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេងៗដែលបានកំណត់មុន ឬនៅពេលទំនិញមកដល់ និងការធានាចំពោះបរិមាណដែលមិនទាន់បានកំណត់ក្នុងទម្រង់ជាវត្ថុធានា ជាប្រាក់កក់ ឬជាឧបករណ៍ទូទាត់សមស្របណាមួយ ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិរបស់សមាជិកនោះ ឬ

(ខ) ការធានាក្នុងទម្រង់ជាវត្ថុធានា ឬជាប្រាក់កក់ ឬជាឧបករណ៍ទូទាត់សមស្របណាមួយ ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិរបស់សមាជិកនោះ។

៣.៣ ការដាក់ធានាបែបនេះ មិនត្រូវលើសបរិមាណដែលសមាជិកនោះត្រូវការដើម្បីធានាចំពោះការទូទាត់ពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេងៗ សម្រាប់ទំនិញដែលត្រូវធានាឡើយ។

៣.៤ ក្នុងករណីរកឃើញថាមានការបំពានដែលតម្រូវឱ្យមានការដាក់ទោសទណ្ឌ ឬពិន័យជាប្រាក់នោះ ការធានាអាចត្រូវបានតម្រូវចំពោះការដាក់ទោសទណ្ឌ និងពិន័យជាប្រាក់ដែលបានកំណត់នោះ។

៣.៥ ការដាក់ធានាដែលមានចែងក្នុងវាក្យខណ្ឌទី៣.២ និងទី៣.៤ នឹងត្រូវបញ្ឈប់ ប្រសិនបើលែងតម្រូវឱ្យមានតទៅទៀត។

៣.៦ គ្មានចំណុចណានៅក្នុងបញ្ញត្តិនេះ ត្រូវប៉ះពាល់ដល់សិទ្ធិនៃសមាជិកក្នុងការត្រួតពិនិត្យ ឃាត់ទុក រឹបអូស ឬដកហូត ឬចាត់វិធានការនានាពាក់ព័ន្ធនឹងទំនិញនោះឡើយ ឱ្យតែការអនុវត្តនោះមិនផ្ទុយនឹងសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកនោះក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

## ៤. ការគ្រប់គ្រងហានិភ័យ

៤.១ តាមការដែលអាចអនុវត្តបាន សមាជិកនីមួយៗត្រូវអនុម័ត ឬរក្សាទុកប្រព័ន្ធគ្រប់គ្រងហានិភ័យសម្រាប់ការត្រួតពិនិត្យគយ។

៤.២ សមាជិកនីមួយៗ ត្រូវបង្កើតនិងអនុវត្តការគ្រប់គ្រងហានិភ័យក្នុងលក្ខណៈមួយដែលចៀសវាងបាននូវការអនុវត្តដោយបំពាន និងគ្មានយុត្តិកម្ម ឬការរឹតត្បិតដោយក្លែងបន្លំលើពាណិជ្ជកម្មអន្តរជាតិ។

៤.៣ សមាជិកនីមួយៗ ត្រូវផ្តោតលើការត្រួតពិនិត្យគយ និងបើអាចអនុវត្តបានត្រូវរួមបញ្ចូលការត្រួតពិនិត្យតាមព្រំដែនពាក់ព័ន្ធផ្សេងទៀតទៅលើទំនិញដែលមានហានិភ័យខ្ពស់ និងត្រូវពន្លឿនការបញ្ចេញទំនិញ

ដែលមានហានិភ័យទាប។ សមាជិកក៏អាចប្រើប្រាស់វិធីសាស្ត្រចៃដន្យដោយជ្រើសរើសទំនិញខ្លះមកត្រួតពិនិត្យ ដែលជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យរបស់ខ្លួន។

៤.៤ សមាជិកនីមួយៗ ត្រូវពឹងផ្អែកការគ្រប់គ្រងហានិភ័យ តាមរយៈការវាយតម្លៃហានិភ័យផ្អែកលើការជ្រើសរើសលក្ខណៈវិនិច្ឆ័យសមស្របមួយចំនួន។ លក្ខណៈវិនិច្ឆ័យជ្រើសរើសនេះ អាចរួមមានលេខកូដប្រព័ន្ធសុខដុមកម្ម លក្ខណៈនិងការបរិយាយនៃទំនិញ ប្រទេសដើមកំណើត ប្រទេសដែលទំនិញត្រូវបានដឹកចេញ តម្លៃទំនិញ ប្រវត្តិនៃអនុលោមភាពរបស់ធុរជន និងប្រភេទនៃមធ្យោបាយដឹកជញ្ជូន។

## ៥. សវនកម្មក្រោយពេលបញ្ចេញទំនិញ

៥.១ដើម្បីពន្លឿនការបញ្ចេញទំនិញ សមាជិកនីមួយៗត្រូវអនុម័ត ឬរក្សាទុកការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញ ដើម្បីធានាអនុលោមភាពជាមួយច្បាប់និងបទប្បញ្ញត្តិគយ និងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

៥.២ សមាជិកនីមួយៗ ត្រូវជ្រើសរើសបុគ្គល ឬទំនិញណាមួយដើម្បីធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញដោយផ្អែកលើហានិភ័យ ដែលរាប់បញ្ចូលនូវលក្ខណៈវិនិច្ឆ័យសមស្រប។ សមាជិកនីមួយៗ ត្រូវធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញប្រកបដោយតម្លាភាព។ ប្រសិនបើមានបុគ្គលម្នាក់ជាប់ពាក់ព័ន្ធក្នុងការធ្វើសវនកម្ម ហើយលទ្ធផលចុងក្រោយត្រូវបានសម្រេច សមាជិកត្រូវជូនដំណឹងទៅបុគ្គលនោះដោយមិនពន្យារពេលអំពីលទ្ធផលនៃការធ្វើសវនកម្ម អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលនោះ និងអំពីមូលហេតុនៃការទទួលបានលទ្ធផលនោះ។

៥.៣ ព័ត៌មានដែលទទួលបានពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញ អាចទុកប្រើប្រាស់បន្តសម្រាប់នីតិវិធីរដ្ឋបាល ឬតុលាការនៅពេលខាងមុខ។

៥.៤ សមាជិកអាចយកលទ្ធផលនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញនេះ ធ្វើជាមូលដ្ឋានគ្រប់គ្រងហានិភ័យ ប្រសិនបើអាចអនុវត្តបាន។

## ៦. ការបង្កើត និងការបោះពុម្ពផ្សាយនូវរយៈពេលមធ្យមនៃការបញ្ចេញទំនិញ

៦.១ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យធ្វើការវាស់វែងនិងបោះពុម្ពផ្សាយនូវរយៈពេលមធ្យមនៃការបញ្ចេញទំនិញតាមកាលកំណត់ជាទៀងទាត់ និងមានសង្គតិភាព ដោយប្រើប្រាស់ឧបករណ៍នានាដូចជា ការសិក្សារយៈពេលបញ្ចេញទំនិញរបស់អង្គការគយពិភពលោក (ហៅកាត់ក្នុងកិច្ចព្រមព្រៀងនេះថា WCO)[៦]។

---

[៦] សមាជិកនីមួយៗអាចកំណត់អំពីវិសាលភាពនិងវិធីសាស្ត្រនៃការវាស់វែងរយៈពេលមធ្យមសម្រាប់ការបញ្ចេញទំនិញ ស្របតាមតម្រូវការ និងសមត្ថភាពរបស់ខ្លួន។

៦.២ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យធ្វើការចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយគណៈកម្មាធិការអំពីការវាស់វែងរយៈពេលមធ្យមនៃការបញ្ចេញទំនិញ រួមទាំងវិធីសាស្ត្រដែលបានប្រើប្រាស់ បញ្ហាប្រឈមដែលរកឃើញ និងផលប៉ះពាល់នៃលទ្ធផលនោះទៅលើប្រសិទ្ធផល។

## ៧. វិធានការកិច្ចសម្រួលពាណិជ្ជកម្មចំពោះប្រតិបត្តិករទទួលបានការអនុញ្ញាត

៧.១ សមាជិកនីមួយៗត្រូវផ្តល់បន្ថែមនូវវិធានការកិច្ចសម្រួលពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងបែបបទ និងនីតិវិធីនាំចូល នាំចេញ និងទំនិញឆ្លងកាត់ ស្របតាមវាក្យខណ្ឌទី៧.៣ ចំពោះប្រតិបត្តិករដែលបំពេញបានតាមលក្ខខណ្ឌកំណត់ ដែលពីពេលនេះតទៅហៅថាប្រតិបត្តិករទទួលបានការអនុញ្ញាត។ សមាជិកក៏អាចមានជម្រើសមួយទៀត ក្នុងការផ្តល់នូវវិធានការកិច្ចសម្រួលពាណិជ្ជកម្មបែបនោះ តាមរយៈនីតិវិធីគយដែលជាទូទៅអាចប្រើប្រាស់បានចំពោះគ្រប់ប្រតិបត្តិករទាំងអស់ ហើយមិនចាំបាច់បង្កើតប្រព័ន្ធដាច់ដោយឡែកឡើយ។

៧.២ លក្ខខណ្ឌជាក់លាក់ដើម្បីក្លាយជាប្រតិបត្តិករទទួលបានការអនុញ្ញាត ត្រូវពាក់ព័ន្ធនឹងអនុលោមភាព ឬហានិភ័យនៃការមិនអនុលោមតាមច្បាប់ ជាមួយនឹងលក្ខខណ្ឌតម្រូវផ្សេងៗដែលបានកំណត់ក្នុងច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់សមាជិក។

(ក) លក្ខណៈវិនិច្ឆ័យទាំងនោះ ដែលត្រូវបោះពុម្ពផ្សាយ រួមមាន÷

(i) កំណត់ត្រានៃអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិគយ និងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

(ii) ប្រព័ន្ធគ្រប់គ្រងកំណត់ត្រា ដែលអនុញ្ញាតឱ្យមានការត្រួតពិនិត្យផ្ទៃក្នុងចាំបាច់

(iii) សាធនភាពហិរញ្ញវត្ថុ ប្រសិនបើអាច រួមទាំងការត្រៀមបម្រុងនិមុត្តធានា ឬការដាក់ធានាគ្រប់គ្រាន់

(iv) និមុត្តធានាខ្សែចង្វាក់ផ្គត់ផ្គង់

(ខ) លក្ខណៈវិនិច្ឆ័យទាំងនោះមិនត្រូវ÷

(i) បង្កើតឡើង ឬដាក់ឱ្យអនុវត្តក្នុងគោលបំណងជួយដល់ ឬបង្កើតឱ្យមានការរើសអើងដោយបំពាន និងគ្មានយុត្តិកម្ម រវាងប្រតិបត្តិករដែលមានលក្ខខណ្ឌដូចគ្នា និង

(ii) រឹតត្បិតដល់ការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យមឡើយ។

៧.៣ វិធានការកិច្ចសម្រួលពាណិជ្ជកម្មដែលបានផ្តល់ស្របតាមវាក្យខណ្ឌទី៧.១ ត្រូវដាក់បញ្ចូលវិធានការយ៉ាងតិចចំនួន៣ ក្នុងចំណោមវិធានការខាងក្រោម[៧]÷

(ក) តម្រូវឱ្យមានឯកសារ និងទិន្នន័យតិចតួចតាមការសមស្រប

(ខ) អត្រានៃអធិការកិច្ច និងការត្រួតពិនិត្យរូបវ័ន្ត មានកម្រិតទាបតាមការសមស្រប

---

[៧] វិធានការដែលមានចែងក្នុងវាក្យខណ្ឌរង ៧.៣ (ក) ដល់ (ឍ) ត្រូវបានចាត់ទុកថាបានផ្តល់ចំពោះប្រតិបត្តិករទទួលបានការអនុញ្ញាត ប្រសិនបើវិធានការនេះត្រូវបានផ្តល់ចំពោះប្រតិបត្តិករជាទូទៅ។

(គ) រយៈពេលនៃការបញ្ចេញទំនិញលឿនតាមការសមស្រប

(ឃ) ការពន្យារពេលនៃការបង់ពន្ធគយ អាករ កម្រៃ និងបន្ទុក

(ង) ការប្រើប្រាស់នូវនិមុត្តធានាពេញលេញ ឬនិមុត្តធានាកាត់បន្ថយ

(ច) ប្រតិវេទន៍គយតែមួយសម្រាប់រាល់ការនាំចូល ឬការនាំចេញក្នុងរយៈពេលមួយកំណត់ និង

(ឆ) ការបញ្ចេញទំនិញនៅទីតាំងរបស់ប្រតិបត្តិករទទួលបានការអនុញ្ញាត ឬនៅទីតាំងផ្សេងទៀតដែលអនុញ្ញាតដោយគយ

៧.៤ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យបង្កើតនូវប្រព័ន្ធប្រតិបត្តិករទទួលបានការអនុញ្ញាតដោយផ្អែកលើស្តង់ដារអន្តរជាតិ ប្រសិនបើមានស្តង់ដារនោះ លើកលែងតែក្នុងករណីដែលស្តង់ដារអន្តរជាតិនោះ មិនស័ក្តសម ឬមិនមានប្រសិទ្ធភាពដើម្បីឈានទៅសម្រេចនូវគោលដៅស្របច្បាប់ដែលចង់បាន។

៧.៥ ដើម្បីបង្កើនប្រសិទ្ធភាពវិធានការកិច្ចសម្រួលពាណិជ្ជកម្មដែលផ្តល់ឱ្យប្រតិបត្តិករ សមាជិកត្រូវបង្កលក្ខណៈងាយស្រួលដល់សមាជិកដទៃទៀត ដើម្បីចរចាកសាងការទទួលស្គាល់គ្នាទៅវិញទៅមកលើប្រព័ន្ធប្រតិបត្តិករទទួលបានការអនុញ្ញាត។

៧.៦ សមាជិក ត្រូវផ្លាស់ប្តូរព័ត៌មានគ្នាជាមួយគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម អំពីប្រព័ន្ធប្រតិបត្តិករទទួលបានការអនុញ្ញាតដែលកំពុងអនុវត្តជាធរមាន។

## ៨. ការបញ្ជូនទំនិញលឿន

៨.១ សមាជិកនីមួយៗ ត្រូវអនុម័តឬរក្សាទុកនីតិវិធីដែលអនុញ្ញាតឱ្យមានការបញ្ចេញទំនិញបានលឿន យ៉ាងហោចណាស់សម្រាប់ទំនិញដែលចូលមកតាមផ្លូវអាកាស ដល់បុគ្គលដែលស្នើសុំប្រព្រឹត្តកម្មលឿននេះ ដោយរក្សាទុកការពិនិត្យគយនៅដដែល[៨]។ ប្រសិនបើសមាជិកកំណត់លក្ខណៈវិនិច្ឆ័យ[៩] ដើម្បីរឹតត្បឹតប្រភេទអ្នកស្នើសុំនូវប្រព្រឹត្តកម្មបែបនេះ តាមរយៈលក្ខណៈវិនិច្ឆ័យដែលបានបោះពុម្ពផ្សាយ សមាជិកនោះ ត្រូវកំណត់លក្ខខណ្ឌនានាសម្រាប់អ្នកដាក់ពាក្យសុំដើម្បីឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការដាក់ពាក្យសុំប្រព្រឹត្តកម្មដូចមានចែងក្នុងវាក្យខណ្ឌទី៨.២ ចំពោះការបញ្ជូនទំនិញលឿនរបស់ខ្លួន÷

(ក) ផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងការទូទាត់ចំណាយគយគ្រប់គ្រាន់ ពាក់ព័ន្ធនឹងដំណើរការនៃការបញ្ជូនទំនិញលឿន ក្នុងករណីដែលអ្នកស្នើសុំបំពេញបានតាមលក្ខខណ្ឌតម្រូវរបស់សមាជិកសម្រាប់ដំណើរការនេះ ដែលត្រូវធ្វើឡើងនៅទីតាំងដែលបានកំណត់។

(ខ) ផ្តល់ជាមុននូវឯកសារចាំបាច់នានាដើម្បីការអនុញ្ញាតឱ្យយកទំនិញលឿនចេញ

---

[៨] ក្នុងករណីដែលសមាជិក មានរួចជាស្រេចនូវនីតិវិធីផ្តល់ប្រព្រឹត្តិកម្ម ដូចមានចែងក្នុងវាក្យខណ្ឌទី៨.២ បញ្ញត្តិនេះមិនតម្រូវឱ្យសមាជិកដាក់ចេញនូវនីតិវិធីដាច់ដោយឡែកមួយទៀតសម្រាប់ពន្លឿនការបញ្ចេញទំនិញឡើយ។

[៩] លក្ខណៈវិនិច្ឆ័យសម្រាប់ការដាក់ពាក្យសុំនេះ ប្រសិនបើមាន គឺជាលក្ខខណ្ឌតម្រូវបន្ថែមរបស់សមាជិកសម្រាប់ប្រតិបត្តិចំពោះទំនិញ ឬការបញ្ជូនទំនិញទាំងអស់ដែលនាំចូលតាមច្រកទ្វារផ្លូវអាកាស។

(គ) កំណត់កម្រៃដែលត្រូវបង់ត្រឹមប្រហាក់ប្រហែលនឹងតម្លៃសេវាដែលបានផ្តល់ក្នុងការផ្តល់ប្រព្រឹត្តកម្ម ដែលមានចែងក្នុងវាក្យខណ្ឌទី៨.២

(ឃ) រក្សាទុកការត្រួតពិនិត្យកម្រិតខ្ពស់លើការបញ្ជូនទំនិញលឿន តាមរយៈការប្រើប្រាស់សន្តិសុខផ្ទៃក្នុង ភស្តុភារ និងបច្ចេកវិទ្យាតាមដានការបញ្ជូនទំនិញ គិតចាប់តាំងពីពេលទទួលរហូតដល់ពេលប្រគល់ទំនិញ

(ង) ផ្តល់ការបញ្ជូនទំនិញលឿន គិតចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ទំនិញ

(ច) ទទួលខុសត្រូវរាល់ការបង់ពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេងៗជូនទៅអាជ្ញាធរគយចំពោះទំនិញ

(ឆ) មានកំណត់ត្រាល្អនៃអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិគយ និងច្បាប់និងបទប្បញ្ញត្តិដទៃទៀត

(ជ) គោរពតាមលក្ខខណ្ឌផ្សេងៗទៀតពាក់ព័ន្ធផ្ទាល់ទៅនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវនៃនីតិវិធីរបស់សមាជិកដែលពាក់ព័ន្ធ ជាពិសេសទៅនឹងការផ្តល់ប្រព្រឹត្តកម្ម ដូចមានចែងក្នុងវាក្យខណ្ឌទី៨.២។

៨.២ យោងតាមវាក្យខណ្ឌទី៨.១ និង៨.៣ សមាជិកត្រូវ÷

(ក) កាត់បន្ថយជាអប្បបរមាចំពោះឯកសារតម្រូវសម្រាប់ការបញ្ចេញទំនិញលឿន ស្របតាមវាក្យខណ្ឌទី១ នៃមាត្រា១០ ហើយប្រសិនបើអាចផ្តល់នូវការបញ្ចេញទំនិញផ្អែកលើការផ្តល់ឯកសារតែមួយលើកនូវព័ត៌មានស្តីពីការបញ្ជូនទំនិញជាក់លាក់ណាមួយ

(ខ) ធ្វើយ៉ាងណាឱ្យទំនិញដែលចង់បញ្ជូនលឿននោះ ត្រូវបានបញ្ចេញពីគយក្នុងកាលៈទេសៈធម្មតាបានលឿនតាមដែលអាចធ្វើទៅបាន បន្ទាប់ពីទំនិញនោះមកដល់ ប្រសិនបើព័ត៌មានដែលត្រូវការសម្រាប់ការបញ្ចេញទំនិញនោះត្រូវបានផ្តល់រួចហើយ

(គ) ត្រូវខិតខំប្រឹងប្រែងក្នុងការផ្តល់នូវប្រព្រឹត្តិកម្មដែលមានចែងក្នុងវាក្យខណ្ឌរង (ក) និង (ខ) ដល់ការដឹកជញ្ជូនគ្រប់ប្រភេទទម្ងន់ និងតម្លៃ ដោយត្រូវទទួលស្គាល់ថាសមាជិកត្រូវបានអនុញ្ញាតឱ្យដាក់បន្ថែមនូវនីតិវិធីនាំចូល រួមមានប្រតិវេទន៍ និងឯកសារជំនួយនានា និងការបង់ពន្ធគយ អាករ និងធ្វើការដាក់កម្រិតប្រព្រឹត្តិកម្មបែបនេះផ្អែកលើប្រភេទទំនិញ ប្រសិនបើប្រព្រឹត្តិកម្មបែបនេះ មិនត្រូវបានដាក់កម្រិតត្រឹមទំនិញដែលមានតម្លៃទាបដូចជាឯកសារជាដើម និង

(ឃ) ប្រសិនបើអាច ត្រូវបែងចែករវាងការដឹកជញ្ជូនទំនិញដែលមានតម្លៃអប្បបរមា ឬបរិមាណប្រាក់ជាប់ពន្ធអប្បបរមា ដែលមិនត្រូវប្រមូលប្រាក់ពន្ធ ត្រូវដាក់ឱ្យដាច់ដោយឡែកពីទំនិញដែលជាប់ពន្ធ។ ពន្ធក្នុងស្រុក ដូចជាពន្ធលើតម្លៃបន្ថែម និងពន្ធអាករ ដែលត្រូវអនុវត្តចំពោះការនាំចូលដែលស្របតាមមាត្រា៣ នៃកិច្ចព្រមព្រៀងស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ (GATT 1994) គឺពុំមែនជាកម្មវត្ថុនៃបញ្ញត្តិនេះទេ។

៨.៣ គ្មានអ្វីទាំងអស់នៅក្នុងវាក្យខណ្ឌទី៨.១ និង ៨.២ ដែលនឹងប៉ះពាល់ដល់សិទ្ធិរបស់សមាជិកមួយ ក្នុងការពិនិត្យ ឃាត់ទុក រឹបអូស ដកហូត ឬបដិសេធការនាំទំនិញចូល ឬការធ្វើសវនកម្មក្រោយពេល

បញ្ចេញទំនិញ រួមបញ្ចូលនូវការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យផង។ លើសពីនេះទៀត គ្មានអ្វីទាំងអស់នៅក្នុងវាក្យខណ្ឌទី៨.១ និងទី៨.២ ដែលនឹងរារាំងសមាជិកមួយមិនឱ្យដាក់ការតម្រូវចំពោះការផ្តល់ព័ត៌មានបន្ថែម និងការបំពេញតាមលក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណមិនស្វ័យប្រវត្តិ ដែលជាលក្ខខណ្ឌសម្រាប់ការបញ្ចេញទំនិញបានឡើយ។

## ៩. ទំនិញងាយខូច[១០]

៩.១ ដើម្បីបង្ការខាតបង់ ឬការបាត់បង់គុណភាពនៃទំនិញងាយខូចដែលគួរជៀសវាងបាន និងក្នុងករណីលក្ខខណ្ឌតម្រូវនានាត្រូវបានបំពេញ សមាជិកនីមួយៗត្រូវអនុញ្ញាតឱ្យមានការបញ្ចេញទំនិញងាយខូច÷

(ក) នៅក្នុងកាលៈទេសៈធម្មតា ត្រូវបញ្ចេញទំនិញឱ្យបានឆាប់បំផុត តាមការដែលអាចធ្វើបាន និង

(ខ) នៅក្នុងកាលៈទេសៈពិសេស ប្រសិនបើអាចធ្វើបាន ត្រូវបញ្ចេញទំនិញនៅក្រៅម៉ោងធ្វើការរបស់គយ និងអាជ្ញាធរពាក់ព័ន្ធនានា

៩.២ សមាជិកនីមួយៗ ត្រូវផ្តល់អាទិភាពដល់ទំនិញងាយខូច ប្រសិនបើតម្រូវឱ្យមានការកំណត់កាលបរិច្ឆេទសម្រាប់ត្រួតពិនិត្យទំនិញ។

៩.៣ សមាជិកនីមួយៗ ត្រូវរៀបចំ ឬអនុញ្ញាតឱ្យអ្នកនាំចូលរៀបចំកន្លែងស្តុកទំនិញងាយខូចឱ្យបានសមស្របនៅពេលរង់ចាំការបញ្ចេញទំនិញ។ សមាជិក អាចតម្រូវថារាល់ទីតាំងស្តុកទំនិញដែលរៀបចំដោយអ្នកនាំចូលត្រូវមានការយល់ព្រម និងកំណត់ដោយអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសខ្លួន។ ការបញ្ជូនទំនិញទៅកាន់ទីតាំងស្តុកទំនិញទាំងនោះ រួមទាំងការផ្តល់សិទ្ធិឱ្យប្រតិបត្តិករបញ្ជូនទំនិញទាំងនោះ ត្រូវទទួលបានការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ។ តាមការស្នើសុំរបស់អ្នកនាំចូល ប្រសិនបើអាចអនុវត្តបាន និងអនុលោមតាមបទប្បញ្ញត្តិក្នុងស្រុក សមាជិកត្រូវផ្តល់នីតិវិធីចាំបាច់នានាសម្រាប់ការបញ្ចេញទំនិញនៅតាមទីតាំងស្តុកទំនិញទាំងនោះ។

៩.៤ ក្នុងករណីមានការពន្យារពេលយូរក្នុងការបញ្ចេញទំនិញងាយខូច និងផ្អែកតាមការស្នើសុំជាលាយលក្ខណ៍អក្សរ សមាជិកជាអ្នកនាំចូលត្រូវបញ្ជាក់មូលហេតុដែលនាំឱ្យមានការពន្យារពេលនោះ តាមការដែលអាចធ្វើទៅបាន។

---

[១០] សម្រាប់គោលបំណងនៃបញ្ញត្តិនេះ ទំនិញងាយខូចគឺជាប្រភេទទំនិញដែលឆាប់ស្អុយរលួយដោយសារចរិតលក្ខណៈធម្មជាតិនៃទំនិញ ជាពិសេស នៅពេលអវត្តមាននៃលក្ខខណ្ឌស្តុកទុកមិនសមស្រប។

## មាត្រា ៨÷ កិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារព្រំដែន

**១.** សមាជិកនីមួយៗ ត្រូវធានាថាអាជ្ញាធរនិងទីភ្នាក់ងារដែលទទួលបន្ទុកអនុវត្តការងារត្រួតពិនិត្យតាមព្រំដែន និងនីតិវិធីពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និងឆ្លងកាត់នៃទំនិញ មានកិច្ចសហប្រតិបត្តិការជាមួយគ្នា និងសម្របសម្រួលការងាររបស់ខ្លួនដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម។

**២.** ប្រសិនបើអាច និងតាមការដែលអាចអនុវត្តបាន សមាជិកនីមួយៗ ត្រូវសហការជាមួយសមាជិកដទៃទៀតដែលមានព្រំដែនជាប់គ្នា ផ្អែកតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាទៅវិញទៅមកក្នុងគោលបំណងជួយសម្រួលលើការងារនីតិវិធីនៅច្រកព្រំដែនដើម្បជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែន។ កិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលនេះ អាចរួមមាន÷

(ក) រៀបចំឱ្យមានម៉ោង និងថ្ងៃធ្វើការដូចគ្នា

(ខ) រៀបចំឱ្យមាននីតិវិធី និងទម្រង់បែបបទដូចគ្នា

(គ) អភិវឌ្ឍន៍ និងប្រើប្រាស់ទីតាំងរួមគ្នា

(ឃ) ត្រួតពិនិត្យរួមគ្នា

(ង) បង្កើតប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនតែមួយ

## មាត្រា ៩÷ ចរាចរណ៍នៃទំនិញដែលមានបំណងនាំចូលក្រោមការត្រួតពិនិត្យគយ

តាមការដែលអាចអនុវត្តបាន និងក្នុងករណីដែលបំពេញនូវបានគ្រប់លក្ខខណ្ឌតម្រូវ សមាជិកនីមួយៗ ត្រូវអនុញ្ញាតឱ្យទំនិញដែលមានបំណងនាំចូល អាចធ្វើចរាចរណ៍នៅក្នុងដែនដីរបស់សមាជិកនោះក្រោមការត្រួតពិនិត្យគយ ពីការិយាល័យគយនៅច្រកនាំចូលទៅកាន់ការិយាល័យគយមួយទៀតនៅក្នុងដែនដីរបស់ខ្លួន ដែលជាកន្លែងត្រូវអនុញ្ញាតឱ្យយកទំនិញចេញ ឬបញ្ចេញទំនិញ។

## មាត្រា ១០÷ បែបបទពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និងការឆ្លងកាត់

### ១. លក្ខខណ្ឌតម្រូវនៃបែបបទនិងឯកសារ

១.១ ក្នុងគោលបំណងកាត់បន្ថយឧប្បត្តិហេតុនិងភាពស៊ីញ៉ាំនៃបែបបទសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ ព្រមទាំងកាត់បន្ថយ និងជួយសម្រួលដល់លក្ខខណ្ឌនៃការរៀបចំឯកសារសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ ក៏ដូចជាពិចារណាលើគោលបំណងនៃគោលនយោបាយផ្នែកច្បាប់ និងកត្តាផ្សេងទៀត ដូចជាបម្រែបម្រួលនៃកាលៈទេសៈ ព័ត៌មានថ្មីដែលពាក់ព័ន្ធនឹងការអនុវត្តក្នុងអាជីវកម្ម ភាពអាចរកបាននៃបច្ចេកទេស និងបច្ចេកវិទ្យា ការអនុវត្តល្អបំផុតជាអន្តរជាតិ និងការផ្តល់ធាតុចូលពីភាគីពាក់ព័ន្ធ សមាជិកត្រូវពិនិត្យឡើងវិញនូវបែបបទ និងលក្ខខណ្ឌតម្រូវនៃឯកសារទាំងនោះ÷

(ក) ដោយអនុម័ត និង/ឬអនុវត្តក្នុងគោលបំណងបញ្ចេញទំនិញឱ្យបានឆាប់រហ័ស ជាពិសេសទំនិញងាយខូច។

(ខ) ដោយអនុម័ត និង/ឬអនុវត្តក្នុងគោលបំណងកាត់បន្ថយពេលវេលានិងការចំណាយលើអនុលោមភាពរបស់ធុរជន និងប្រតិបត្តិករ។

(គ) ដោយជ្រើសយកវិធានការរឹតត្បិតតិចតួចបំផុត ដែលមានវិធានការអាចជំនួសគ្នាបានពីរ ឬច្រើនសម្រាប់ជ្រើសរើសដើម្បីបំពេញគោលបំណងគោលនយោបាយ ឬគោលបំណងនៃការដោះស្រាយបញ្ហាដែលកើតមាន។

(ឃ) មិនត្រូវរក្សាទុកបន្តទៅទៀតទេ ដោយរាប់ទាំងផ្នែកនានាខាងលើ ប្រសិនបើលែងមានការតម្រូវ។

## ២. ការទទួលយកឯកសារថតចម្លង

២.១ សមាជិកនីមួយៗ ត្រូវទទួលយកឯកសារជាក្រដាស ឬឯកសារអេឡិកត្រូនិក នៃឯកសារគាំទ្រដែលជាការតម្រូវសម្រាប់បែបបទនៃការនាំចូល ការនាំចេញ និងការឆ្លងកាត់ តាមដែលធ្វើទៅបាន។

២.២ នៅពេលដែលទីភ្នាក់ងាររដ្ឋាភិបាលនៃសមាជិកមួយ កាន់កាប់រួចហើយនូវឯកសារច្បាប់ដើម ទីភ្នាក់ងារផ្សេងទៀតនៃសមាជិកនោះ ត្រូវទទួលយកឯកសារថតចម្លង ឬឯកសារអេឡិកត្រូនិកពីទីភ្នាក់ងារដែលកាន់កាប់ឯកសារដើម ជំនួសឱ្យឯកសារច្បាប់ដើម តាមដែលធ្វើបាន។

២.៣ សមាជិក មិនត្រូវទាមទារច្បាប់ដើម ឬច្បាប់ចម្លងនៃប្រតិវេទន៍នាំចេញ ដែលបានប្រគល់ជូនអាជ្ញាធរគយនៃសមាជិកនាំចេញ ធ្វើជាលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូលទេ[១១]។

## ៣. ការប្រើប្រាស់ស្តង់ដារអន្តរជាតិ

៣.១ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ស្តង់ដារអន្តរជាតិពាក់ព័ន្ធ ឬផ្នែកនានារបស់វា ធ្វើជាមូលដ្ឋានសម្រាប់ទម្រង់បែបបទ និងនីតិវិធីនៃការនាំចូល ការនាំចេញ និងការឆ្លងកាត់របស់ពួកគេលើកលែងតែមានចែងផ្សេងក្រៅពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ។

៣.២ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យចូលរួម ផ្អែកតាមកម្រិតធនធានរបស់ពួកគេក្នុងការរៀបចំ និងត្រួតពិនិត្យជាទៀងទាត់នូវស្តង់ដារអន្តរជាតិពាក់ព័ន្ធធ្វើឡើងដោយអង្គការអន្តរជាតិពាក់ព័ន្ធ។

៣.៣ គណៈកម្មាធិការ ត្រូវបង្កើតនីតិវិធីសម្រាប់ការចែករំលែកព័ត៌មាន និងការអនុវត្តល្អបំផុតពាក់ព័ន្ធនឹងការអនុវត្តស្តង់ដារអន្តរជាតិ ក្នុងចំណោមសមាជិកនានាតាមការសមស្រប។

គណៈកម្មាធិការក៏អាចអញ្ជើញអង្គការអន្តរជាតិពាក់ព័ន្ធនានា មកពិភាក្សាអំពីការងារទាក់ទងនឹងស្តង់ដារអន្តរជាតិផងដែរ។ គណៈកម្មាធិការក៏អាចកំណត់ស្តង់ដាជាក់លាក់ដែលមានតម្លៃសម្រាប់សមាជិក ប្រសិនបើសមស្រប។

---

[១១] ពុំមានអ្វីនៅក្នុងវាក្យខណ្ឌនេះ ដែលនឹងរារាំងសមាជិកមិនឱ្យទាមទារឯកសារនានា ដូចជា វិញ្ញាបនបត្រ លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូលនូវទំនិញដែលត្រូវត្រួតពិនិត្យ ឬនិយ័តឡើយ។

## ៤. បញ្ជរតែមួយ

៤.១ សមាជិកទាំងអស់ ត្រូវខិតខំប្រឹងប្រែងបង្កើត និងរក្សាទុកនូវបញ្ជរតែមួយ ដែលអាចជួយសម្រួលដល់ធុរជនក្នុងការផ្តល់ឯកសារ និង/ឬលក្ខខណ្ឌតម្រូវនៃទិន្នន័យសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ តាមរយៈច្រកតែមួយទៅកាន់អាជ្ញាធរ ឬទីភ្នាក់ងារពាក់ព័ន្ធ។ បន្ទាប់ពីអាជ្ញាធរ ឬទីភ្នាក់ងារពាក់ព័ន្ធបានត្រួតពិនិត្យឯកសារ និង/ឬទិន្នន័យរួច អាជ្ញាធរ ឬទីភ្នាក់ងារនោះត្រូវជូនដំណឹងអំពីលទ្ធផលទៅអ្នកដាក់ពាក្យសុំវិញ តាមរយៈបញ្ជរតែមួយឱ្យបានទាន់ពេលវេលា។

៤.២ ក្នុងករណីដែលលក្ខខណ្ឌតម្រូវនៃឯកសារនិង/ឬទិន្នន័យត្រូវបានទទួលតាមរយៈបញ្ជរតែមួយ លក្ខខណ្ឌតម្រូវនៃឯកសារនិង/ទិន្នន័យដដែលនោះ នឹងមិនត្រូវបានស្នើសុំដោយអាជ្ញាធរ ឬទីភ្នាក់ងារពាក់ព័ន្ធទៀតឡើយ លើកលែងតែក្នុងកាលៈទេសៈបន្ទាន់ និងក្នុងករណីលើកលែងតិចតួចផ្សេងទៀតដែលត្រូវបានដឹងជាសាធារណៈប៉ុណ្ណោះ។

៤.៣ សមាជិកនានា ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីព័ត៌មានលម្អិតនៃប្រតិបត្តិការបញ្ជរតែមួយ។

៤.៤ ក្នុងលក្ខណៈដែលអាចធ្វើទៅរួច និងអាចអនុវត្តបាន សមាជិកនានាត្រូវប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មានដើម្បីទ្រទ្រង់បញ្ជរតែមួយ។

## ៥. អធិការកិច្ចទំនិញមុនពេលផ្ទុក

៥.១ សមាជិកនានា មិនតម្រូវឱ្យប្រើសេវាអធិការកិច្ចទំនិញមុនពេលផ្ទុកពាក់ព័ន្ធនឹងចំណាត់ថ្នាក់តាមតារាងពន្ធគយ និងការកំណត់តម្លៃគិតពន្ធគយនោះទេ។

៥.២ ដោយពុំរើសអើងដល់សិទ្ធិរបស់សមាជិកនានា ក្នុងការប្រើសប្រាស់ប្រភេទសេវាអធិការកិច្ចទំនិញមុនពេលផ្ទុកផ្សេងទៀតដែលពុំមានចែងក្នុងវាក្យខណ្ឌ ៥.១ សមាជិកត្រូវបានលើកទឹកចិត្តមិនឱ្យដាក់ចេញឬអនុវត្តលក្ខខណ្ឌតម្រូវផ្សេងទៀតឡើយ[១២]។

## ៦. ការប្រើប្រាស់ជើងសារគយ

៦.១ ដោយពុំរើសអើងចំពោះគោលនយោបាយពាក់ព័ន្ធសំខាន់ៗរបស់សមាជិកមួយចំនួនដែលបច្ចុប្បន្នកំពុងផ្តល់តួនាទីពិសេសសម្រាប់ជើងសារគយ ចាប់ពីពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកទាំងឡាយ មិនត្រូវកំណត់ការប្រើប្រាស់ជើងសារគយជាកាតព្វកិច្ចទៀតឡើយ។

៦.២ សមាជិកនីមួយៗ ត្រូវជូនដំណឹងដល់គណៈកម្មាធិការ និងបោះពុម្ពផ្សាយវិធានការនានារបស់ខ្លួនស្តីពីការប្រើជើងសារគយ។ រាល់ការកែប្រែណាមួយពាក់ព័ន្ធនឹងវិធានការនោះ ត្រូវជូនដំណឹង និងបោះពុម្ពផ្សាយជាបន្ទាន់។

---

[១២] វាក្យខណ្ឌនេះសំដៅលើអធិការកិច្ចទំនិញមុនពេលផ្ទុក ដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក និងមិនដកចេញនូវអធិការកិច្ចទំនិញមុនពេលផ្ទុកសម្រាប់គោលបំណងអនាម័យនិងភូតគាមអនាម័យឡើយ។

៦.៣ ពាក់ព័ន្ធទៅនឹងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ជើងសារគយ សមាជិកទាំងឡាយត្រូវអនុវត្តនូវវិធានការនានា ដែលមានតម្លាភាព និងចំកម្មវត្ថុ។

## ៧. នីតិវិធីរួមតាមព្រំដែន និងលក្ខខណ្ឌតម្រូវនៃឯកសារដូចគ្នា

៧.១ យោងតាមវាក្យខណ្ឌ ៧.២ សមាជិកម្នាក់ៗត្រូវអនុវត្តនីតិវិធីគយរួម និងលក្ខខណ្ឌតម្រូវនៃឯកសារដូចគ្នាសម្រាប់ការអនុញ្ញាតឱ្យយកទំនិញចេញនិងការបញ្ចេញទំនិញនៅក្នុងដែនដីរបស់ខ្លួនទាំងមូល។

៧.២ គ្មានអ្វីទាំងអស់នៅក្នុងប្រការនេះ ដែលនឹងរារាំងសមាជិកមិនឱ្យ÷

(ក) មានភាពខុសគ្នាលើនីតិវិធីនិងលក្ខខណ្ឌតម្រូវឯកសារផ្សេងៗ ដោយផ្អែកតាមលក្ខណៈ និងប្រភេទនៃទំនិញ ឬមធ្យោបាយដឹកជញ្ជូនទំនិញ។

(ខ) មានភាពខុសគ្នាលើនីតិវិធីនិងលក្ខខណ្ឌតម្រូវឯកសារផ្សេងៗដោយផ្អែកលើការគ្រប់គ្រងហានិភ័យ។

(គ) មានភាពខុសគ្នាលើនីតិវិធីនិងលក្ខខណ្ឌតម្រូវឯកសារផ្សេងៗ ដើម្បីផ្តល់ការលើកលែងទាំងស្រុង ឬភាគខ្លះនៃពន្ធ ឬអាករនាំចូល ។

(ឃ) អនុវត្តការបំពេញបែបបទ ឬដំណើរការតាមអេឡិកត្រូនិក ឬ

(ង) មានភាពខុសគ្នាលើនីតិវិធី និងលក្ខខណ្ឌតម្រូវឯកសារផ្សេងៗ ស្របតាមកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យ។

## ៨. ទំនិញបដិសេធ

៨.១ នៅពេលដែលទំនិញសម្រាប់ការនាំចូលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចនៃសមាជិកមួយបដិសេធដោយមូលហេតុពុំអនុលោមតាមបទប្បញ្ញត្តិអនាម័យនិងភូតគាមអនាម័យ ឬបទបញ្ញត្តិបច្ចេកទេសដែលមានចែង ក្រោមលក្ខខណ្ឌនិងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ សមាជិកត្រូវអនុញ្ញាតឱ្យអ្នកនាំចូលបញ្ជូនទំនិញនោះត្រឡប់ទៅវិញ ឬប្រគល់ទំនិញនោះទៅអ្នកនាំចេញ ឬបុគ្គលដែលត្រូវបានចាត់តាំងជាតំណាងអ្នកនាំចេញ។

៨.២ នៅពេលដែលជម្រើសក្រោមវាក្យខណ្ឌ ៨.១ ត្រូវបានធ្វើឡើង ហើយអ្នកនាំចូលនៅតែមិនអាចអនុវត្តបានក្នុងអំឡុងពេលមួយសមស្រប អាជ្ញាធរមានសមត្ថកិច្ចអាចប្រើវិធានការផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាជាមួយទំនិញដែលពុំបានអនុលោមតាមលក្ខខណ្ឌនោះ។

## ៩. ការអនុញ្ញាតឱ្យនាំចូលទំនិញជាបណ្តោះអាសន្ន និងការកែច្នៃទំនិញនាំចូលនិងការកែច្នៃទំនិញនាំចេញ???

៩.១ ការអនុញ្ញាតឱ្យនាំចូលទំនិញជាបណ្តោះអាសន្ន

សមាជិកនីមួយៗ ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន ត្រូវអនុញ្ញាតឱ្យនាំទំនិញចូលក្នុងដែនគយរបស់ខ្លួន ក្រោមការលើកលែងការបង់ពន្ធនាំចូល និងអាករទាំងស្រុង ឬភាគខ្លះ ប្រសិនបើទំនិញ

ដែលបាននាំចូលមានគោលបំណងជាក់លាក់សម្រាប់ការនាំចេញទៅវិញក្នុងអំឡុងពេលមួយជាក់លាក់ និងមិនបានធ្វើការផ្លាស់ប្តូរ លើកលែងតែការថយចុះតម្លៃ និងការខាតបង់ជាធម្មតាដោយការប្រើប្រាស់។

៩.២ ការកែច្នៃទំនិញនាំចូល និងការកែច្នៃទំនិញនាំចេញ

(ក) សមាជិកនីមួយៗ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិនានា ត្រូវអនុញ្ញាតឱ្យមានការកែច្នៃទំនិញនាំចូល និងការកែច្នៃទំនិញនាំចេញ។ ទំនិញដែលអនុញ្ញាតឱ្យមានការកែច្នៃក្នុងការនាំចេញ អាចត្រូវបាននាំចូលជាថ្មី ដោយមានការលើកលែងពន្ធ និងអាករសម្រាប់ការនាំចូលទាំងស្រុង ឬមួយផ្នែក ស្រប ច្បាប់ និងបទប្បញ្ញត្តិរបស់សមាជិក។

(ខ) សម្រាប់គោលបំណងនៃវាក្យខណ្ឌនេះ ពាក្យថា "ការកែច្នៃទំនិញនាំចូល" សំដៅលើនីតិវិធីគយដែលទំនិញមួយចំនួនអាចត្រូវបាននាំចូលក្នុងដែនដីគយរបស់សមាជិកក្នុងលក្ខខណ្ឌដែលត្រូវបានលើកលែងពន្ធនិងអាករទាំងស្រុង ឬភាគខ្លះ ឬអាចទទួលយកការបង្វិលសងប្រាក់ពន្ធវិញ ដោយផ្អែកលើមូលដ្ឋានថាទំនិញទាំងនោះ មានគោលដៅសម្រាប់ការផលិត ការកែច្នៃ ឬការជួសជុល និងការនាំចេញក្នុងពេលបន្ទាប់។

(គ) សម្រាប់គោលបំណងនៃវាក្យខណ្ឌនេះ ពាក្យថា "ការកែច្នៃទំនិញនាំចេញ" សំដៅលើនីតិវិធីគយដែលទំនិញត្រូវបានអនុញ្ញាតឱ្យចរាចរដោយសេរីក្នុងដែនគយរបស់សមាជិក ដែលអាចត្រូវបាននាំចេញជាបណ្តោះអាសន្នសម្រាប់ការផលិត ការកែច្នៃ ឬការជួសជុលនៅបរទេស និងបន្ទាប់មកនាំចូលមកវិញ។

## ប្រការ ១១÷ សេរីភាពនៃការឆ្លងកាត់

**១.** បទប្បញ្ញត្តិ ឬបែបបទទាំងឡាយពាក់ព័ន្ធនឹងចរាចរឆ្លងកាត់ ដែលសមាជិកដាក់ឱ្យអនុវត្តមិនត្រូវ÷

(ក) រក្សាទុក ប្រសិនបើកាលៈទេសៈ ឬគោលបំណងដែលនាំឱ្យមានការអនុម័តនោះលែងមានតទៅទៀត ឬប្រសិនបើការផ្លាស់ប្តូរកាលៈទេសៈ ឬគោលបំណងនោះ អាចត្រូវបានធ្វើឡើងតាមរបៀបផ្សេងដែលមានការរឹតត្បិតពាណិជ្ជកម្មតិចជាង។

(ខ) អនុវត្តក្នុងរបៀបមួយដែលអាចបង្កើតបានជាការបិទបាំងលើការរឹតត្បិតសម្រាប់ការចរាចរឆ្លងកាត់។

**២.** ការចរាចរឆ្លងកាត់មិនត្រូវយកមកធ្វើជាលក្ខខណ្ឌ បន្ទាប់ពីការប្រមូលកម្រៃ ឬបន្ទុកដែលបានអនុវត្តសម្រាប់ការឆ្លងកាត់ លើកលែងតែបន្ទុកចំណាយសម្រាប់ការដឹកជញ្ជូន ឬចំណាយសមាមាត្រទៅនឹងចំណាយរដ្ឋបាលដែលបានកំណត់សម្រាប់ការឆ្លងកាត់ ឬចំណាយលើសេវាដែលមាននោះ។

**៣.** សមាជិកទាំងឡាយមិនត្រូវស្វែងរក ទទួលយក ឬរក្សាការដាក់កំហិតដោយស្ម័គ្រចិត្ត ឬវិធានការស្រដៀងគ្នាផ្សេងទៀតពាក់ព័ន្ធនឹងចរាចរឆ្លងកាត់ឡើយ។ នេះពុំទាន់គិតដល់បទប្បញ្ញត្តិថ្នាក់ជាតិ ការរៀបចំទ្វេភាគី ឬពហុភាគីបច្ចុប្បន្ន និងអនាគត ដែលពាក់ព័ន្ធនឹងការកំណត់បញ្ញត្តិសម្រាប់ការដឹកជញ្ជូនដែលអនុលោមតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក។

៤. សមាជិកនីមួយៗត្រូវអនុលោមតាមទំនិញដែលនឹងត្រូវឆ្លងកាត់ តាមដែនដីនៃការអនុវត្តរបស់សមាជិកផ្សេងទៀត ដែលមិនត្រូវមានលក្ខខណ្ឌអំណោយផលតិចជាងលក្ខខណ្ឌដែលយកមកអនុវត្តចំពោះទំនិញទាំងនោះ ប្រសិនបើទំនិញនោះត្រូវដឹកជញ្ជូនចេញពីប្រទេសដើមកំណើត ទៅកាន់គោលដៅចុងក្រោយរបស់ពួកគេ ដោយមិនបានឆ្លងកាត់ដែនដីនៃសមាជិកផ្សេងទៀតនោះ។

៥. សមាជិកទាំងឡាយ ត្រូវបានលើកទឹកចិត្តឱ្យបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដាច់ដោយឡែក (ដូចជាគន្លងផ្លូវ កន្លែងចតនាវា ឬកន្លែងប្រហាក់ប្រហែលផ្សេងទៀត) សម្រាប់ចរាចរការឆ្លងកាត់តាមដែលអាចអនុវត្តបាន។

៦. បែបបទ លក្ខខណ្ឌតម្រូវនៃឯកសារ និងការត្រួតពិនិត្យគយពាក់ព័ន្ធនឹងចរាចរឆ្លងកាត់មិនត្រូវដាក់បន្ទុកបន្ថែមក្នុងការ÷

(ក) កំណត់មុខទំនិញ និង

(ខ) ធានានូវការបំពេញលក្ខខណ្ឌនៃការឆ្លងកាត់ឡើយ។

៧. នៅពេលដែលទំនិញត្រូវបានដាក់ក្រោមនីតិវិធីឆ្លងកាត់ និងត្រូវបានអនុញ្ញាតឱ្យដឹកបន្តចាប់ពីចំណុចដើមនៅក្នុងដែនដីរបស់សមាជិក ទំនិញទាំងនោះ មិនតម្រូវឱ្យចំណាយបន្ទុកគយណាមួយ ឬការពន្យារពេល ឬការរឹតត្បិតដែលមិនចាំបាច់ រហូតទាល់តែការឆ្លងកាត់ត្រូវបានបញ្ចប់នៅឯចំណុចគោលដៅនៅក្នុងដែនដីរបស់សមាជិក។

៨. សមាជិក មិនត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីវាយតម្លៃការអនុលោមតាមអត្ថន័យនៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះការធ្វើពាណិជ្ជកម្មទំនិញឆ្លងកាត់ឡើយ។

៩. សមាជិកទាំងឡាយ ត្រូវអនុញ្ញាតនិងផ្តល់នូវការរក្សាទុក និងដំណើរការនៃឯកសារនិងទិន្នន័យនៃការឆ្លងកាត់ជាមុន មុនពេលទំនិញមកដល់។

១០. នៅពេលដែលចរាចរឆ្លងកាត់បានទៅដល់ការិយាល័យគយ ដែលជាកន្លែងទំនិញត្រូវបានចេញពីក្នុងដែនដីរបស់សមាជិក ការិយាល័យនោះត្រូវបញ្ចប់ប្រតិបត្តិការឆ្លងកាត់ ប្រសិនបើលក្ខខណ្ឌតម្រូវនៃការឆ្លងកាត់ត្រូវបានបំពេញ។

១១. ប្រសិនបើសមាជិក តម្រូវឱ្យមានការធានាក្នុងទម្រង់ជាការធានាដោយវត្ថុ ការតម្កល់ប្រាក់ ឬមធ្យោបាយជាសាច់ប្រាក់ ឬមិនមែនជាសាច់ប្រាក់[១៣] ផ្សេងទៀតសម្រាប់ចរាចរឆ្លងកាត់ ការធានានោះត្រូវកំណត់ឱ្យបានថាលក្ខខណ្ឌតម្រូវដែលកើតពីការចរាចរឆ្លងកាត់ត្រូវបានបំពេញ។

---

[១៣] ពុំមានបញ្ញត្តិណាក្នុងវាក្យខណ្ឌនេះដែលនឹងរារាំងសមាជិកពីការរក្សាទុកនីតិវិធីមានស្រាប់ ដែលតាមនីតិវិធីនោះ មធ្យោបាយដឹកជញ្ជូនអាចត្រូវបានប្រើប្រាស់ជាការធានាសម្រាប់ចរាចរឆ្លងកាត់។

**១២.** នៅពេលដែលសមាជិកបានកំណត់ថាលក្ខខណ្ឌក្នុងការឆ្លងកាត់របស់ខ្លួនត្រូវបានបំពេញ ការធានាត្រូវលុបចោលដោយពុំបង្អែរបង្អង់ឡើយ។

**១៣.** ក្នុងលក្ខណៈដែលស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា សមាជិកម្នាក់ៗត្រូវអនុញ្ញាតឱ្យមានការធានាទូលំទូលាយ ដែលរួមបញ្ចូលទាំងប្រតិបត្តិការចម្រុះសម្រាប់ប្រតិបត្តិករដូចគ្នា ឬការបន្តធានាសារជាថ្មី ដោយពុំមានការលើកលែងចំពោះការប្រគល់ទំនិញត្រឡប់វិញក្នុងពេលបន្ទាប់។

**១៤.** សមាជិកនីមួយៗ ត្រូវធ្វើយ៉ាងណាឱ្យព័ត៌មានពាក់ព័ន្ធអាចរកបានជាសាធារណៈដែលខ្លួនប្រើសម្រាប់ការធានា រាប់បញ្ចូលទាំងប្រតិបត្តិការតែមួយ និងការធានាចំពោះប្រតិបត្តិការចម្រុះ ក្នុងករណីសមស្រប។

**១៥.** សមាជិកនីមួយៗ អាចតម្រូវឱ្យប្រើប្រាស់ការអម ឬក្បួនការពារគយសម្រាប់ចរាចរឆ្លងកាត់តែក្នុងកាលៈទេសៈដែលមានហានិភ័យខ្ពស់ ឬនៅពេលអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិគយមិនអាចធានាបាន តាមរយៈការប្រើប្រាស់ការធានាទាំងនេះ។ វិធានទូទៅសម្រាប់ការអម ឬក្បួនការពារគយត្រូវផ្សព្វផ្សាយស្របតាមមាត្រា១។

**១៦.** សមាជិកទាំងឡាយ ត្រូវប្រឹងប្រែងសហការ និងសម្របសម្រួលជាមួយគ្នាទៅវិញទៅមកក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសេរីភាពនៃការឆ្លងកាត់។ ការសហការ និងការសម្របសម្រួលបែបនេះ អាចរាប់បញ្ចូលតែមិនកំហិតត្រឹមការយល់ដឹងទៅលើ÷

(ក) បន្ទុកចំណាយ

(ខ) បែបបទ និងលក្ខខណ្ឌតម្រូវនៃច្បាប់ និង

(គ) ប្រតិបត្តិការដែលអាចអនុវត្តបានសម្រាប់របបឆ្លងកាត់

**១៧.** សមាជិកនីមួយៗ ត្រូវខិតខំតែងតាំងអ្នកសម្របសម្រួលការឆ្លងកាត់ថ្នាក់ជាតិ ដែលគ្រប់សំណួរនិងសំណើទាំងអស់ដែលធ្វើឡើងដោយសមាជិកផ្សេងទៀតពាក់ព័ន្ធនឹងមុខងារនៃប្រតិបត្តិការឆ្លងកាត់ អាចត្រូវបានដោះស្រាយ។

## ប្រការ ១២÷ កិច្ចសហប្រតិបត្តិការគយ

### ១. វិធានការលើកកម្ពស់អនុលោមភាពនិងកិច្ចសហប្រតិបត្តិការ

១.១ សមាជិកព្រមព្រៀងលើសារៈសំខាន់នៃការធានាថាធុរជនបានដឹងពីកាតព្វកិច្ចអនុលោមភាព ការលើកទឹកចិត្តអនុលោមភាពដោយស្ម័គ្រចិត្តដើម្បីអនុញ្ញាតឱ្យអ្នកនាំចូលអាចកែកំហុសដោយខ្លួនឯង ដោយពុំមានការដាក់ពិន័យក្នុងស្ថានភាពសមស្រប និងអនុវត្តនូវវិធានការអនុលោមភាពដើម្បីផ្ដួចផ្ដើមឱ្យមានវិធានការតឹងរឹងចំពោះធុរជនណាដែលពុំមានអនុលោមភាព[១៤]។

[១៤] សកម្មភាពបែបនេះ មានបំណងដើម្បីកាត់បន្ថយការពុំមានអនុលោមភាព និងឈានទៅរកការកាត់បន្ថយតម្រូវការចំពោះការផ្លាស់ប្តូរព័ត៌មានសម្រាប់បន្តការអនុវត្តច្បាប់។

១.២ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានអំពីការអនុវត្តល្អក្នុងការគ្រប់គ្រងអនុលោមភាព គយ រួមទាំងតាមរយៈគណៈកម្មាធិការ។ សមាជិក ត្រូវបានលើកទឹកចិត្តឱ្យសហការក្នុងការណែនាំ ឬ ជំនួយបច្ចេកទេស និងការគាំទ្រក្នុងការកសាងសមត្ថភាពក្នុងគោលបំណងគ្រប់គ្រងវិធានការអនុលោម ភាព និងការលើកកម្ពស់ប្រសិទ្ធភាព។

## ២. ការផ្លាស់ប្តូរព័ត៌មាន

២.១ ដោយមានការស្នើសុំនិងយោងតាមបទប្បញ្ញត្តិនៃប្រការនេះ សមាជិកត្រូវផ្លាស់ប្តូរព័ត៌មានដូចមានចែង ក្នុងវាក្យខណ្ឌ ៦.១ (ខ) និង/ឬ (គ) សម្រាប់គោលបំណងផ្ទៀងផ្ទាត់ការប្រកាសនាំចូល ឬនាំចេញក្នុង ករណីដែលបានកំណត់ ប្រសិនបើមានមូលហេតុសមស្របក្នុងការសង្ស័យអំពីការពិត ឬភាពត្រឹមត្រូវ នៃការប្រកាសនោះ។

២.២ សមាជិកនីមួយៗ ត្រូវជូនដំណឹងដល់គណៈកម្មាធិការអំពីព័ត៌មានលម្អិតនៃអ្នកដែលត្រូវទំនាក់ទំនង សម្រាប់ការផ្លាស់ប្តូរព័ត៌មាននេះ។

## ៣. ការផ្ទៀងផ្ទាត់

សមាជិកត្រូវស្នើសុំព័ត៌មាន តែនៅក្រោយពេលដែលខ្លួនបានរៀបចំនីតិវិធីផ្ទៀងផ្ទាត់សមស្របសម្រាប់ការ ប្រកាសការនាំចេញ ឬការនាំចូល និងបន្ទាប់ពីខ្លួនបានពិនិត្យនូវឯកសារពាក់ព័ន្ធដែលមាន។

## ៤. ការស្នើសុំ

៤.១ សមាជិកដាក់សំណើ ត្រូវផ្តល់ជូនសមាជិកទទួលសំណើនូវការស្នើសុំជាលាយលក្ខណ៍អក្សរតាម មធ្យោបាយជាឯកសារ ឬមធ្យោបាយអេឡិកត្រូនិក ដោយប្រើភាសាផ្លូវការរួមគ្នាមួយកំណត់ដោយ អង្គការពាណិជ្ជកម្មពិភពលោក ឬភាសាផ្សេងទៀតដែលបានព្រមព្រៀងគ្នា រួមទាំង÷

(ក) បញ្ហាកំពុងកើតមាន រួមទាំងចំនួនដែលកំណត់ពីការប្រកាសការនាំចេញ ដែលត្រូវគ្នានឹងការប្រកាស ការនាំចូល ដែលបានស្នើសុំសមស្របនិងអាចរកបាន។

(ខ) គោលបំណងដែលសមាជិកដាក់សំណើ កំពុងស្វែងរកព័ត៌មាន ឬឯកសារ រួមជាមួយឈ្មោះ និង ព័ត៌មានទំនាក់ទំនងនៃបុគ្គលដែលពាក់ព័ន្ធនឹងការស្នើសុំ ប្រសិនបើស្គាល់។

(គ) ប្រសិនបើមានការតម្រូវពីសមាជិកទទួលសំណើនូវការបញ្ជាក់[១៥]នៃការផ្ទៀតផ្ទាត់ដែលសមស្រប។

(ឃ) ព័ត៌មាន ឬឯកសារជាក់លាក់ដែលបានស្នើសុំ។

(ង) អត្តសញ្ញាណនៃការិយាល័យដើមដែលបានស្នើសុំ។

---

[១៥] នេះអាចរួមបញ្ចូលនូវព័ត៌មានទាក់ទងទៅនឹងការផ្ទៀងផ្ទាត់ដែលបានធ្វើឡើងក្រោមវាក្យខណ្ឌ ៣។ ព័ត៌មានទាំងនោះ ត្រូវអនុលោមតាមកម្រិតនៃការការពារ និងការរក្សាការសម្ងាត់ដោយសមាជិកដែលធ្វើការផ្ទៀតផ្ទាត់។

(ច) យោងទៅលើបញ្ញត្តិនៃច្បាប់និងប្រព័ន្ធច្បាប់ក្នុងស្រុករបស់សមាជិកដាក់សំណើ ដែលគ្រប់គ្រងការប្រមូល ការការពារ ការប្រើប្រាស់ ការបញ្ចេញឱ្យដឹង ការរក្សាទុក និងការបំផ្លាញចោលនូវព័ត៌មានសម្ងាត់ និងព័ត៌មានផ្ទាល់ខ្លួន។

៤.២ ប្រសិនបើសមាជិកដាក់សំណើ មិនបានអនុលោមតាមវាក្យខណ្ឌរងនៃកថាខណ្ឌ ៤.១ សមាជិកនោះត្រូវបញ្ជាក់នៅក្នុងសំណើសុំនេះ។

## ៥. ការការពារនិងការសម្ងាត់

៥.១ យោងតាមវាក្យខណ្ឌ ៥.២ សមាជិកដាក់សំណើត្រូវ÷

(ក) រក្សាព័ត៌មាន ឬឯកសារទាំងអស់ ដែលផ្ដល់ដោយសមាជិកទទួលសំណើជាការសម្ងាត់ និងត្រូវផ្ដល់ការការពារ និងការរក្សាការសម្ងាត់ក្នុងកម្រិតដូចគ្នា ដូចមានចែងក្នុងច្បាប់និងប្រព័ន្ធច្បាប់ក្នុងស្រុករបស់សមាជិកទទួលសំណើ ដែលមានចែងក្នុងវាក្យខណ្ឌ ៦.១ (ខ) ឬ (គ)។

(ខ) ផ្ដល់ព័ត៌មាន ឬឯកសារឱ្យតែចំពោះអាជ្ញាធរគយពាក់ព័ន្ធនឹងបញ្ហាដែលកើតមាន និងប្រើប្រាស់ព័ត៌មាន ឬឯកសារតែសម្រាប់គោលបំណងដូចមានចែងក្នុងសំណើ លើកលែងតែសមាជិកទទួលសំណើព្រមព្រៀងផ្សេងពីនេះជាលាយលក្ខណ៍អក្សរ។

(គ) មិនបញ្ចេញព័ត៌មាន ឬឯកសារ ដោយពុំមានការអនុញ្ញាតជាក់លាក់ជាលាយលក្ខណ៍អក្សរពីសមាជិកទទួលសំណើ។

(ឃ) មិនប្រើព័ត៌មាន ឬឯកសារដែលពុំទាន់បានផ្ទៀងផ្ទាត់ពីសមាជិកទទួលសំណើជាការសម្រេចចិត្តចំពោះការលុបបំបាត់នូវការសង្ស័យទោះក្នុងស្ថានភាពណាក៏ដោយ។

(ង) គោរពតាមលក្ខខណ្ឌជាក់លាក់ដែលពាក់ព័ន្ធនឹងករណី ដូចមានចែងដោយសមាជិកទទួលសំណើពាក់ព័ន្ធនឹងការរក្សាទុកនិងការកំទេចចោលនូវព័ត៌មាន ឬឯកសារសម្ងាត់ និងទិន្នន័យផ្ទាល់ខ្លួន។

(ច) បន្ទាប់ពីស្នើសុំ ត្រូវជូនដំណឹងដល់សមាជិកទទួលសំណើនូវរាល់សេចក្ដីសម្រេចចិត្តនិងសកម្មភាពដែលបានអនុវត្តចំពោះបញ្ហាដែលជាលទ្ធផលនៃព័ត៌មាន ឬឯកសារដែលបានផ្ដល់ជូន។

៥.២ សមាជិកដាក់សំណើ អាចមិនអនុវត្តបានតាមច្បាប់និងប្រព័ន្ធច្បាប់ក្នុងស្រុកដើម្បីឱ្យមានអនុលោមភាពតាមវាក្យខណ្ឌរងនៃវាក្យខណ្ឌ ៥.១។ ប្រសិនបើដូច្នេះ សមាជិកដាក់សំណើត្រូវបញ្ជាក់បញ្ហានេះនៅក្នុងសំណើ។

៥.៣ សមាជិកទទួលសំណើ ត្រូវផ្តល់ប្រព្រឹត្តកម្មចំពោះសំណើណាមួយនិងការផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន ក្រោមវាក្យខណ្ឌ ៤ យ៉ាងហោចណាស់ក្នុងកម្រិតដូចគ្នានៃការការពារ និងរក្សាការសម្ងាត់ ដែលបានព្រមព្រៀងដោយសមាជិកទទួលសំណើចំពោះសំណើស្រដៀងគ្នារបស់ខ្លួន។

## ៦. បញ្ញត្តិនៃព័ត៌មាន

៦.១ យោងតាមបទបញ្ញត្តិនៃប្រការនេះ សមាជិកទទួលសំណើត្រូវប្រញាប់៖

(ក) ឆ្លើយតបជាលាយលក្ខណ៍អក្សរ តាមរយៈមធ្យោបាយឯកសារ ឬតាមអេឡិចត្រូនិច

(ខ) ផ្តល់ព័ត៌មានជាក់លាក់ ដូចមានចែងក្នុងប្រតិវេទន៍នាំចូល និងនាំចេញ ឬការប្រកាស ក្នុងកម្រិត ដែលអាចធ្វើបានស្របតាមការចែងពីកម្រិតនៃការការពារ និងការរក្សាការសម្ងាត់ដែលចាំបាច់នៃសមាជិកដាក់សំណើ។

(គ) ផ្តល់ព័ត៌មានជាក់លាក់ដូចមានចែងក្នុងឯកសារខាងក្រោម ឬឯកសារនានា ប្រសិនបើមានការស្នើសុំដោយប្រគល់នូវឯកសារគាំទ្រដល់ប្រតិវេទន៍នាំចេញ ឬនាំចូល ក្នុងកម្រិតដែលអាចរកបាននូវ៖ វិក្កយបត្រពាណិជ្ជកម្ម បញ្ជីវេចខ្ចប់ វិញ្ញាបនបត្រដើមកំណើត និងអាជ្ញាប័ណ្ណ ក្នុងទម្រង់ដែលឯកសារនោះត្រូវរក្សាទុក ទោះជាឯកសារជាក្រដាស ឬជាអេឡិកត្រូនិក ស្របតាមការចែងពីកម្រិតនៃការការពារ និងការរក្សាការសម្ងាត់ដែលចាំបាច់នៃសមាជិកដែលបានស្នើសុំ។

(ឃ) បញ្ជាក់ថាឯកសារដែលបានផ្តល់គឺជាឯកសារថតចម្លងត្រឹមត្រូវ

(ង) ផ្តល់ព័ត៌មាន ឬការឆ្លើយតបផ្សេងពីនេះទៅនឹងការស្នើសុំ ក្នុងកម្រិតដែលអាចធ្វើបាន ក្នុងអំឡុង ៩០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទស្នើសុំ។

៦.២ សមាជិកទទួលសំណើអាចតម្រូវឱ្យមានការធានា ដោយអនុលោមតាមច្បាប់និងប្រព័ន្ធច្បាប់ក្នុងស្រុកមុនពេលផ្តល់ព័ត៌មានថាព័ត៌មានជាក់លាក់ មិនត្រូវបានយកទៅប្រើប្រាស់ធ្វើជាការបញ្ជាក់ក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋ ដំណើរការក្តីតុលាការ ឬដំណើរការមិនមែនតុលាការ ដោយពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសមាជិកទទួលសំណើឡើយ។ ប្រសិនបើសមាជិកទទួលសំណើពុំស្ថិតក្នុងស្ថានភាពដែលអនុលោមតាមលក្ខខណ្ឌតម្រូវនេះ សមាជិកត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីបញ្ហានេះទៅសមាជិកទទួលសំណើ។

## ៧. ការពន្យារ ឬការបដិសេធសំណើ

៧.១ សមាជិកទទួលសំណើ អាចពន្យារ ឬបដិសេធផ្នែកណាមួយ ឬទាំងស្រុងនូវសំណើសុំឱ្យផ្តល់ព័ត៌មាន និងត្រូវជូនដំណឹងដល់សមាជិកដាក់សំណើអំពីមូលហេតុនៃការធ្វើដូចនោះ ប្រសិនបើ៖

(ក) ការស្នើសុំអាចផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈដូចមានចែងក្នុងច្បាប់ និងប្រព័ន្ធច្បាប់ក្នុងស្រុករបស់សមាជិកទទួលសំណើ។

(ខ) ច្បាប់ និងប្រព័ន្ធច្បាប់ក្នុងស្រុក រារាំងដល់ការបញ្ចេញព័ត៌មាន។ ក្នុងករណីបែបនេះ សមាជិកត្រូវផ្តល់ជូនសមាជិកដាក់សំណើនូវច្បាប់ចម្លងនៃឯកសារយោងពាក់ព័ន្ធ។

(គ) ការផ្តល់ព័ត៌មានអាចអាក់ខានដល់ការអនុវត្តច្បាប់ ឬការរំខានផ្សេងពីនេះពីការស៊ើបអង្កេតផ្នែករដ្ឋបាល ឬតុលាការ ការកាត់ទោស ឬដំណើរការក្តីកំពុងបន្ត។

(ឃ) ការយល់ព្រមរបស់អ្នកនាំចូល ឬអ្នកនាំចេញ ត្រូវបានតម្រូវដោយច្បាប់ និងប្រព័ន្ធច្បាប់ក្នុងស្រុក ដែលគ្រប់គ្រងលើការប្រមូល ការការពារ ការប្រើប្រាស់ ការបញ្ចេញ ការរក្សាទុក និងការកំទេចចោលនូវព័ត៌មានសម្ងាត់ ឬទិន្នន័យផ្ទាល់ខ្លួន ហើយការយល់ព្រមនោះមិនត្រូវបានផ្តល់ជូន ឬ

(ង) សំណើសុំផ្តល់ព័ត៌មានត្រូវបានទទួលបន្ទាប់ពីផុតកំណត់នូវលក្ខខណ្ឌតម្រូវផ្នែកច្បាប់របស់សមាជិកទទួលសំណើសម្រាប់ការរក្សាទុកឯកសារ។

៧.២ ក្នុងកាលៈទេសៈនៃវាក្យខណ្ឌ ៤.២, ៥.២, ឬ ៦.២ ការអនុវត្តសំណើបែបនេះ ត្រូវធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់សមាជិកទទួលសំណើ។

## ៨. បដិការ

ប្រសិនបើសមាជិកដាក់សំណើ គិតថាខ្លួនមិនអាចអនុវត្តតាមសំណើសុំស្រដៀងគ្នានេះ ប្រសិនបើសំណើត្រូវបានធ្វើឡើងដោយសមាជិកទទួលសំណើ ឬប្រសិនបើខ្លួនពុំទាន់បានអនុវត្តស្របតាមប្រការនេះ សមាជិកដាក់សំណើ ត្រូវបញ្ជាក់អំពីបញ្ហានេះនៅក្នុងសំណើ។ ការអនុវត្តនូវសំណើនេះ ត្រូវធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់សមាជិកទទួលសំណើ។

## ៩. បន្ទុករដ្ឋបាល

៩.១ សមាជិកដាក់សំណើ ត្រូវពិចារណាលើធនធានពាក់ព័ន្ធ និងការចំណាយនានា សម្រាប់សមាជិកទទួលសំណើ ក្នុងការឆ្លើយតបទៅនឹងការស្នើសុំព័ត៌មាន។ សមាជិកដាក់សំណើ ត្រូវពិចារណាលើសមាមាត្ររវាងផលប្រយោជន៍សារពើពន្ធរបស់ខ្លួនក្នុងការបន្តសំណើ និងកិច្ចខិតខំប្រឹងប្រែងដែលត្រូវធ្វើឡើងដោយសមាជិកទទួលសំណើក្នុងការផ្តល់ព័ត៌មាន។

៩.២ ប្រសិនបើសមាជិកទទួលសំណើ ទទួលបានសំណើជាច្រើនដែលមិនអាចគ្រប់គ្រងបាន ឬសំណើសុំព័ត៌មានក្នុងវិសាលភាពដែលមិនអាចគ្រប់គ្រងបានពីសមាជិកដាក់សំណើមួយ ឬច្រើន និងមិនអាចឆ្លើយតបបានទៅនឹងការស្នើសុំទាំងនោះក្នុងពេលវេលាមួយសមស្រប សមាជិកទទួលសំណើអាចស្នើសុំឱ្យសមាជិកដាក់សំណើមួយ ឬច្រើន បង្កើតអាទិភាពជាក់ស្តែងទៅតាមភាពខ្វះខាតនៃធនធានរបស់សមាជិកទទួលសំណើនោះ។ ក្នុងករណីដែលពុំមានយន្តការព្រមព្រៀងគ្នាទៅវិញទៅមក ការអនុវត្តតាមសំណើសុំនោះ ត្រូវធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់សមាជិកទទួលសំណើ ដោយផ្អែកលើលទ្ធផលនៃការផ្តល់អាទិភាពរបស់ខ្លួន។

## ១០. ការដាក់កំហិត

សមាជិកទទួលសំណើ មិនតម្រូវឱ្យ÷

(ក) កែសម្រួលទម្រង់នៃប្រតិវេទន៍ឬនីតិវិធីនាំចូល ឬនាំចេញរបស់ខ្លួនឡើយ

(ខ) ស្នើសុំឯកសារផ្សេងក្រៅពីឯកសារទាំងឡាយណា ដែលបានប្រគល់សម្រាប់ការប្រកាសការនាំចូល ឬនាំចេញ ដូចមានចែងក្នុងវាក្យខណ្ឌ ៦.១ (គ)។

(គ) បង្កើតចម្លល់ដើម្បីទទួលបានព័ត៌មាន

(ឃ) កែប្រែអំឡុងពេលនៃការរក្សាទុកឯកសារទាំងនោះ

(ង) ដាក់ចេញឱ្យប្រើឯកសារជាក្រដាស ខណៈដែលឯកសារទម្រង់ជាអេឡិកត្រូនិកត្រូវបានដាក់ឱ្យប្រើប្រាស់រួចហើយ

(ច) បកប្រែឯកសារ

(ឆ) ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មាន ឬ

(ជ) ផ្តល់ព័ត៌មានដែលអាចធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់នៃសហគ្រាសជាក់លាក់ ទោះជារដ្ឋ ឬឯកជន។

## ១១. ការមិនអនុញ្ញាតឱ្យប្រើប្រាស់ ឬលាតត្រដាងព័ត៌មាន

១១.១ ក្នុងករណីមានការបំពានលើលក្ខខណ្ឌណាមួយនៃការប្រើប្រាស់ ឬលាតត្រដាងព័ត៌មានដែលផ្តល់ឱ្យគ្នាទៅវិញទៅមក ស្របតាមប្រការនេះ សមាជិកដាក់សំណើដែលទទួលបានព័ត៌មាន ត្រូវផ្តល់ដំណឹងជាបន្ទាន់អំពីការប្រើប្រាស់ ឬលាតត្រដាងព័ត៌មានដែលពុំបានអនុញ្ញាតនោះ ទៅកាន់សមាជិកទទួលសំណើដែលផ្តល់ព័ត៌មាន និង÷

(ក) ចាត់វិធានការចាំបាច់ដើម្បីដោះស្រាយលើការបំពាន

(ខ) ចាត់វិធានការចាំបាច់ដើម្បីការពារការបំពាននាពេលអនាគត និង

(គ) ជូនដំណឹងដល់សមាជិកទទួលសំណើអំពីវិធានការដែលបានធ្វើឡើងស្របតាមវាក្យខណ្ឌ (ក)និង(ខ)។

១១.២ សមាជិកទទួលសំណើ អាចផ្អាកកាតព្វកិច្ចរបស់ខ្លួនចំពោះសមាជិកដាក់សំណើ ស្របតាមប្រការនេះ រហូតទាល់តែវិធានការដូចមានចែងក្នុងកថាខណ្ឌ ១១.១ ត្រូវបានអនុវត្ត។

## ១២. កិច្ចព្រមព្រៀងទ្វេភាគី និងតំបន់

១២.១ ពុំមានបញ្ញត្តិណាមួយក្នុងមាត្រានេះ អាចរារាំងសមាជិកណាមួយមិនឱ្យចុះកិច្ចព្រមព្រៀងទ្វេភាគីពហុភាគី ឬកិច្ចព្រមព្រៀងថ្នាក់តំបន់សម្រាប់ការចែករំលែក ឬផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យគយ រួមទាំង

កិច្ចព្រមព្រៀងដែលផ្អែកលើមូលដ្ឋានសុវត្ថិភាព និងឆាប់រហ័ស ដូចជា មូលដ្ឋានស្វ័យប្រវត្តិ ឬមុនការមកដល់នៃទំនិញ។

១២.២ ពុំមានបញ្ញត្តិណាមួយក្នុងមាត្រានេះ អាចត្រូវបានបកស្រាយថាជាការផ្លាស់ប្ដូរ ឬការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ឬកាតព្វកិច្ចរបស់សមាជិកក្រោមកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ឬកិច្ចព្រមព្រៀងតំបន់ ឬថាជាការគ្រប់គ្រងការផ្លាស់ប្ដូរព័ត៌មាន និងទិន្នន័យគយ ស្របតាមកិច្ចព្រមព្រៀងផ្សេងទៀត។

## ផ្នែកទី២

## បញ្ញត្តិស្ដីពីប្រព្រឹត្តកម្មពិសេស និងដោយឡែក សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួចបំផុត ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

### មាត្រា ១៣÷ គោលការណ៍ទូទៅ

**១.** បញ្ញត្តិនានាដូចមានចែងក្នុងមាត្រា ១ ដល់មាត្រា ១២ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តដោយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចដោយអនុលោមតាមផ្នែកនេះ ផ្អែកលើទម្រង់គំរូនានាដែលបានព្រមព្រៀងគ្នានៅក្នុងឧបសម្ព័ន្ធ “ឃ” ក្រោមក្របខណ្ឌនៃកិច្ចព្រមព្រៀង ខែកក្កដា ឆ្នាំ២០០៤ (ឯកសារលេខ WT/L/579) និងក្នុងវាក្យខណ្ឌទី៣៣ និងឧបសម្ព័ន្ធ “ង” នៃសេចក្ដីថ្លែងការណ៍រដ្ឋមន្ត្រីនៅទីក្រុងហុងកុង (ឯកសារលេខ WT/MIN(05)/DEC)។

**២.** ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព[១៦] ត្រូវបានផ្ដល់ដើម្បីជួយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកប្រទេសអភិវឌ្ឍន៍តិចតួចអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ស្របតាមខ្លឹមសារនិងវិសាលភាពនៃកិច្ចព្រមព្រៀង។ វិសាលភាព និងរយៈពេលនៃការអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ត្រូវអាស្រ័យលើសមត្ថភាពក្នុងការអនុវត្តរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច។ ក្នុងករណីសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច នៅបន្ដខ្វះខាតសមត្ថភាពចាំបាច់ដើម្បីអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ប្រទេសសមាជិកនោះនឹងមិនត្រូវបានបង្ខំឱ្យអនុវត្តបញ្ញត្តិពាក់ព័ន្ធនោះឡើយ រហូតទាល់តែសមាជិកនោះ មានសមត្ថភាពអនុវត្តគ្រប់គ្រាន់សិន។

**៣.** សមាជិកដែលជាប្រទេសអភិវឌ្ឍន៍តិចតួច នឹងតម្រូវឱ្យអនុវត្តការសន្យារបស់ខ្លួនតែនៅក្នុងលក្ខណៈមួយដែលស្របតាមកម្រិតនៃការអភិវឌ្ឍន៍ តម្រូវការហិរញ្ញវត្ថុនិងពាណិជ្ជកម្ម ឬស្របតាមសមត្ថភាពរដ្ឋបាល ឬស្ថាប័នរបស់សមាជិកនោះប៉ុណ្ណោះ។

**៤.** គោលការណ៍ទាំងនោះ នឹងត្រូវអនុវត្តលើបញ្ញត្តិទាំងអស់ដែលមានចែងក្នុងផ្នែកទី២។

---

[១៦] សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ “ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព” អាចធ្វើឡើងក្នុងទម្រង់ជាជំនួយបច្ចេកទេស ជំនួយហិរញ្ញវត្ថុ ឬក្នុងទម្រង់នៃការផ្ដល់ជំនួយដទៃទៀត ដែលព្រមព្រៀងដោយភាគីទាំងសងខាង។

## មាត្រា ១៤÷ ប្រភេទនៃបញ្ញត្តិ

**១.** ប្រភេទនៃបញ្ញត្តិបែងចែកជាបីគឺ÷

(ក) ប្រភេទ "A" រួមមានបញ្ញត្តិនានាដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច កំណត់ថាអាចអនុវត្តបានភ្លាម នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ឬក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវអនុវត្តបានរយៈពេលមួយឆ្នាំក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ដូចមានចែងក្នុងមាត្រា១៥។

(ខ) ប្រភេទ "B" រួមមានបញ្ញត្តិនានាដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច កំណត់ថាអាចអនុវត្តបាននៅកាលបរិច្ឆេទណាមួយបន្ទាប់ពីរយៈពេលអន្តរកាលក្រោយពីកិច្ចព្រមព្រៀងនេះ ចូលជាធរមានដូចមានចែងក្នុងមាត្រា១៦។

(គ) ប្រភេទ "C" រួមមានបញ្ញត្តិនានាដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច កំណត់ថាអាចអនុវត្តបាននៅកាលបរិច្ឆេទណាមួយបន្ទាប់ពីរយៈពេលអន្តរកាលក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយទាមទារនូវសមត្ថភាពអនុវត្តតាមរយៈការផ្តល់ជំនួយ និងការឧបត្ថម្ភសម្រាប់ការកសាងសមត្ថភាព ដូចមានចែងក្នុងមាត្រា១៦។

**២.** សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចនីមួយៗ ត្រូវកំណត់ដោយខ្លួនឯង និងផ្អែកលើមូលដ្ឋានរៀងៗខ្លួន ក្នុងការដាក់បញ្ចូលបញ្ញត្តិនានាទៅក្នុងប្រភេទ A, B, និង C។

## មាត្រា១៥÷ ការជូនដំណឹងនិងការអនុវត្តបញ្ញត្តិប្រភេទ A

**១.** នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវអនុវត្តបញ្ញត្តិប្រភេទ A ។ ដូច្នេះ ការសន្យាដែលបានកំណត់នៅក្រោមប្រភេទ A នឹងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

**២.** សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច អាចជូនដំណឹងទៅគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្មអំពីបញ្ញត្តិនានាដែលខ្លួនបានកំណត់ជាប្រភេទ A ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ រាល់ការសន្យារបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍តិចតួចដែលបានកំណត់នៅក្រោមបញ្ញត្តិប្រភេទ A នឹងក្លាយទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៦÷ ការផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទពិតប្រាកដសម្រាប់ការអនុវត្តបញ្ញត្តិប្រភេទ B និងប្រភេទ C

**១.** ចំពោះបញ្ញត្តិនានាដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍មិនបានកំណត់ជាបញ្ញតិប្រភេទ A សមាជិកនោះអាចពន្យារពេលអនុវត្ត ស្របតាមនីតិវិធីនានាដែលបានកំណត់នៅក្នុងមាត្រានេះ។

**បញ្ញត្តិប្រភេទ B នៃសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍**

(ក) នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗ ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្មអំពីបញ្ញត្តិនានា ដែលខ្លួនបានកំណត់ក្នុងប្រភេទ B និងកាលបរិច្ឆេទសម្រាប់អនុវត្ត[១៧]។

(ខ) ក្នុងរយៈពេលមិនលើសមួយឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗ ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីកាលបរិច្ឆេទពិតប្រាកដសម្រាប់អនុវត្តបញ្ញត្តិនានាដែលបានកំណត់ក្នុងប្រភេទ B។ ប្រសិនបើនៅមុនពេលផុតកាលបរិច្ឆេទខាងលើ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍យល់ឃើញថា ខ្លួនត្រូវការពេលវេលាបន្ថែមក្នុងការជូនដំណឹងអំពីកាលបរិច្ឆេទពិតប្រាកដ សមាជិកនោះអាចស្នើសុំគណៈកម្មាធិការដើម្បីពន្យារពេលឱ្យបានគ្រប់គ្រាន់សម្រាប់ជូនដំណឹងអំពីកាលបរិច្ឆេទពិតប្រាកដរបស់ខ្លួន។

**បញ្ញត្តិប្រភេទ C នៃសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍**

(គ) នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីបញ្ញត្តិនានាដែលខ្លួនបានកំណត់ក្នុងប្រភេទ C និងកាលបរិច្ឆេទសមស្របសម្រាប់អនុវត្ត។ សម្រាប់គោលបំណងតម្លាភាព ការផ្តល់ព័ត៌មាននោះត្រូវរួមបញ្ចូលនូវព័ត៌មានស្តីពីការផ្តល់ជំនួយ និងការគាំទ្រលើការកសាងសមត្ថភាពដែលសមាជិកត្រូវការសម្រាប់អនុវត្តកិច្ចព្រមព្រៀង[១៨]។

(ឃ) ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសផ្តល់ជំនួយ ដោយពិចារណាលើយន្តការដែលមានស្រាប់ និងការផ្តល់ព័ត៌មានស្របតាមវាក្យខណ្ឌ១ នៃមាត្រា ២២ និងព័ត៌មានដែលបានផ្តល់ជូនដូចមានចែងក្នុងវាក្យខណ្ឌរង “គ” ខាងលើ ត្រូវជូនដំណឹងទៅគណៈកម្មាធិការអំពីយន្តការមានស្រាប់ ឬកំពុងកើតមាន ដែលចាំបាច់សម្រាប់ការផ្តល់ជំនួយនិងការគាំទ្រលើការកសាងសមត្ថភាពសម្រាប់អនុវត្តបញ្ញត្តិប្រភេទ C[១៩]។ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ដែលចូលរួម ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅគណៈកម្មាធិការអំពីយន្តការទាំងនេះ។ គណៈកម្មាធិការត្រូវអញ្ជើញអ្នកផ្តល់ជំនួយដែលមិនមែនជាសមាជិកឱ្យផ្តល់ព័ត៌មានស្តីពីយន្តការដែលមានស្រាប់និងយន្តការដែលទើបសម្រេចបាន។

---

[១៧] ការផ្តល់ជូនព័ត៌មានជូនគណៈកម្មាធិការ អាចរួមបញ្ចូលផងដែរនូវព័ត៌មានបន្ថែម ប្រសិនបើសមាជិកដែលត្រូវផ្តល់ព័ត៌មានយល់ថាសមស្រប។ សមាជិកត្រូវបានលើកទឹកចិត្តឱ្យផ្តល់ព័ត៌មានអំពីទីភ្នាក់ងារ ឬអង្គភាពក្នុងស្រុកដែលទទួលខុសត្រូវលើការអនុវត្ត។

[១៨] សមាជិកអាចរួមបញ្ចូលព័ត៌មានស្តីពីផែនការ ឬគម្រោងសម្រាប់អនុវត្តការងារសម្រួលពាណិជ្ជកម្មជាតិ ទីភ្នាក់ងារ ឬអង្គភាពក្នុងស្រុក ដែលទទួលខុសត្រូវលើការអនុវត្ត និងម្ចាស់ជំនួយដែលសមាជិកមានយន្តការទំនាក់ទំនងសម្រាប់ការផ្តល់ជំនួយ។

[១៩] យន្តការទាំងនេះ ត្រូវមានការព្រមព្រៀងគ្នាទៅវិញទៅមកលើលក្ខខណ្ឌនានា ក្រោមរូបភាពទ្វេភាគី ឬតាមរយៈអង្គការអន្តរជាតិសមស្របណាមួយ ស្របតាមវាក្យខណ្ឌទី៣ នៃមាត្រា២១។

(ង) ក្នុងរយៈពេល ១៨ ខែគិតចាប់ពីថ្ងៃផ្តល់ព័ត៌មានដែលមានចែងក្នុងវាក្យខណ្ឌរង “ឃ” សមាជិកដែលជាប្រទេសផ្តល់ជំនួយ និងសមាជិកប្រទេសកំពុងអភិវឌ្ឍន៍ត្រូវជូនដំណឹងទៅគណៈកម្មាធិការអំពីវឌ្ឍនភាពនៃការផ្តល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព។ ទន្ទឹមនេះ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍នីមួយៗ ត្រូវផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទពិតប្រាកដសម្រាប់ការអនុវត្តផងដែរ។

**២.** ចំពោះបញ្ញត្តិនានាដែលសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចមិនបានកំណត់ក្នុងប្រភេទ A សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច អាចពន្យារពេលអនុវត្តផ្អែកតាមនីតិវិធីដែលមានចែងក្នុងមាត្រានេះ។

**បញ្ញត្តិប្រភេទ B នៃសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច**

(ក) ក្នុងរយៈពេលមិនលើសមួយឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីបញ្ញត្តិនានាដែលកំណត់ជាប្រភេទ B និងអាចផ្តល់ព័ត៌មានអំពីគម្រោងកាលបរិច្ឆេទសម្រាប់អនុវត្តបទប្បញ្ញត្តិទាំងនេះ ដោយគិតគូរពិចារណាដល់ភាពបត់បែនអតិបរមាចំពោះសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច។

(ខ) នៅក្នុងរយៈពេលមិនលើសពីរឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្តល់ព័ត៌មាន ដែលមានចែងវាក្យខណ្ឌរង (ក) ខាងលើ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចនីមួយៗ ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការដើម្បីបញ្ជាក់អំពីការកំណត់បញ្ញត្តិនានា និងត្រូវផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទសម្រាប់ការអនុវត្តផងដែរ។ ប្រសិនបើនៅមុនពេលផុតកាលកំណត់ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចយល់ឃើញថាត្រូវការផ្តល់ពេលវេលាបន្ថែមសម្រាប់ការផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទជាក់លាក់ សមាជិកនោះអាចស្នើសុំគណៈកម្មាធិការពន្យារពេលឱ្យបានគ្រប់គ្រាន់សម្រាប់ផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទជាក់លាក់របស់ខ្លួនបាន។

**បញ្ញត្តិប្រភេទ C នៃសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច**

(គ) ដើម្បីឱ្យមានតម្លាភាព និងដើម្បីសម្រួលដល់ការរៀបចំយន្តការជាមួយប្រទេសផ្តល់ជំនួយ ក្នុងរយៈពេលមួយឆ្នាំក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុតនីមួយៗត្រូវផ្តល់ព័ត៌មានទៅគណៈកម្មាធិការអំពីបញ្ញត្តិនានាដែលខ្លួនបានកំណត់ជាប្រភេទ C ដោយគិតគូរដល់ភាពបត់បែនអតិបរមាសម្រាប់ជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុត។

(ឃ) មួយឆ្នាំក្រោយពីកាលបរិច្ឆេទដែលមានចែងក្នុងវាក្យខណ្ឌរង (គ) ខាងលើ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុត ត្រូវផ្តល់ព័ត៌មានអំពីជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ដែលសមាជិកនោះត្រូវការដើម្បីអាចអនុវត្តបញ្ញត្តិនោះបាន[២០]។

---

[២០] សមាជិកអាចរួមបញ្ចូលព័ត៌មានស្តីពីផែនការ ឬគម្រោងសម្រាប់អនុវត្តការងារសម្រួលពាណិជ្ជកម្មជាតិ ទីភ្នាក់ងារ ឬអង្គភាពក្នុងស្រុក ដែលទទួលខុសត្រូវលើការអនុវត្ត និងម្ចាស់ជំនួយ ដែលសមាជិកមានយន្តការទំនាក់ទំនងសម្រាប់ការផ្តល់ជំនួយ។

(ង) យ៉ាងយូរពីរឆ្នាំក្រោយកាលបរិច្ឆេទនៃការផ្តល់ព័ត៌មានដែលមានចែងក្នុងវាក្យខណ្ឌរង (ឃ) ខាងលើ ដោយផ្អែកលើព័ត៌មានដែលបានផ្តល់ផ្អែកតាមវាក្យខណ្ឌរង (ឃ) ខាងលើ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច និងសមាជិកផ្តល់ជំនួយពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីយន្តការមានស្រាប់ ឬកំពុងកើតមាន ហើយដែលចាំបាច់សម្រាប់ការផ្តល់ជំនួយ និងការគាំទ្រដល់ការកសាងសមត្ថភាព ដើម្បីអនុវត្តបញ្ញត្តិប្រភេទ C[២៧]។ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចដែលចូលរួមក្នុងការទទួលជំនួយ ត្រូវផ្តល់ព័ត៌មានភ្លាមៗដល់គណៈកម្មាធិការអំពីយន្តការទាំងនេះ។ ទន្ទឹមនេះដែរ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវផ្តល់ព័ត៌មានអំពីគម្រោងបរិច្ឆេទសម្រាប់ការអនុវត្តការសន្យាប្រភេទ C ដែលត្រូវទទួលជំនួយនិងការគាំទ្រ។ គណៈកម្មាធិការ ត្រូវអញ្ជើញផងដែរនូវអ្នកផ្តល់ជំនួយដែលមិនមែនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ឱ្យផ្តល់ព័ត៌មានស្តីពីយន្តការដែលមានស្រាប់ និងយន្តការដែលទើបសម្រេចបាន។

(ច) មិនឱ្យហួស ១៨ ខែ គិតចាប់ពីថ្ងៃផ្តល់ព័ត៌មាន ដូចមានចែងក្នុងវាក្យខណ្ឌរង (ង) សមាជិកជាម្ចាស់ជំនួយ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវជូនដំណឹងដល់គណៈកម្មាធិការ អំពីវឌ្ឍនភាពនៃការផ្តល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព។ ទន្ទឹមនេះដែរ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចនីមួយៗ ត្រូវជូនដំណឹងដល់គណៈកម្មាធិការនេះអំពីបញ្ជីនៃកាលបរិច្ឆេទជាក់លាក់សម្រាប់ការអនុវត្ត។

៣. សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលជួបប្រទះការលំបាកក្នុងកំណត់កាលបរិច្ឆេទជាក់លាក់សម្រាប់ការអនុវត្តតាមកាលបរិច្ឆេទកំណត់ ដូចមានចែងក្នុងវាក្យខណ្ឌ១ និងវាក្យខណ្ឌ២ ដោយមូលហេតុខ្វះការគាំទ្រពីប្រទេសផ្តល់ជំនួយ ឬខ្វះវឌ្ឍនភាពក្នុងការផ្តល់ជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ត្រូវផ្តល់ព័ត៌មានទៅគណៈកម្មាធិការឱ្យបានឆាប់តាមដែលអាចធ្វើបាន នៅមុនផុតកាលបរិច្ឆេទកំណត់។ បណ្តាសមាជិកបានព្រមព្រៀងគ្នាក្នុងការសហការជួយដោះស្រាយការលំបាកទាំងនោះ ដោយគិតគូរដល់កាលៈទេសៈដោយឡែក និងបញ្ហាពិសេសដែលកំពុងប្រឈមដោយសមាជិកពាក់ព័ន្ធ។ តាមការសមស្រប គណៈកម្មាធិការត្រូវចាត់វិធានការដោះស្រាយការលំបាកទាំងនេះ និងប្រសិនបើចាំបាច់ ត្រូវពន្យារកាលបរិច្ឆេទផុតកំណត់សម្រាប់សមាជិកពាក់ព័ន្ធនោះ ធ្វើការផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទជាក់លាក់។

៤. រយៈពេលបីខែមុនកាលបរិច្ឆេទផុតកំណត់ដែលមានចែងក្នុងវាក្យខណ្ឌរង១(ខ) ឬ (ង) ឬក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដូចមានចែងក្នុងវាក្យខណ្ឌរង២(ខ) ឬ (ច) លេខាធិការដ្ឋានត្រូវក្រើនរំលឹក ប្រសិនបើសមាជិកនោះ មិនបានផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទពិតប្រាកដសម្រាប់ការអនុវត្តបញ្ញត្តិនានាដែលសមាជិកបានកំណត់ជាប្រភេទB ឬប្រភេទC។ ប្រសិនបើសមាជិកមិនប្រើប្រាស់វាក្យខណ្ឌទី៣ ឬនៅក្នុងករណីវាក្យខណ្ឌរង១(ខ)

[២៧] យន្តការនៃការរៀបចំទាំងនេះ ត្រូវមានការព្រមព្រៀងគ្នាទៅវិញទៅមកលើលក្ខខណ្ឌនានា ទោះជាក្នុងលក្ខណៈទ្វេភាគី ឬផ្តល់តាមរយៈអង្គការអន្តរជាតិ ដោយអនុលោមតាមវាក្យខណ្ឌ ៣ នៃមាត្រា២១។

នៃសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬក្នុងករណីវាក្យខណ្ឌរង២(ខ) នៃសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីធ្វើការពន្យារពេលកាលបរិច្ឆេទផុតកំណត់ និងមិនផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទជាក់លាក់សម្រាប់ការអនុវត្ត សមាជិកនោះត្រូវអនុវត្តបញ្ញត្តិនោះក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ ដូចមានចែងក្នុងវាក្យខណ្ឌរង១(ខ) ឬ (ង) ឬក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចដូចមានចែងក្នុងវាក្យខណ្ឌរង២ (ខ) ឬ (ច) ឬត្រូវបានពន្យារពេលដោយប្រើវាក្យខណ្ឌទី៣។

**៥.** មិនឱ្យហួស ៦០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទពិតប្រាកដសម្រាប់ការអនុវត្តបញ្ញត្តិប្រភេទ B និងប្រភេទ C ស្របតាមវាក្យខណ្ឌ១, ២, ឬ៣ គណៈកម្មាធិការត្រូវកត់ត្រានូវឧបសម្ព័ន្ធនានាដែលមានចែងអំពីកាលបរិច្ឆេទនានាដែលបានកំណត់ក្រោមវាក្យខណ្ឌ៤ ដែលធ្វើឱ្យឧបសម្ព័ន្ធនេះ ក្លាយទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៧÷ យន្តការព្រមានជាមុន ÷ ការពន្យារកាលបរិច្ឆេទអនុវត្ត សម្រាប់បញ្ញត្តិប្រភេទ B និងប្រភេទ C

**១.**

(ក) សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលគិតថាកំពុងជួបការលំបាកក្នុងការអនុវត្តបញ្ញត្តិដែលខ្លួនបានកំណត់ក្នុងប្រភេទ B ឬ C នៅត្រឹមកាលបរិច្ឆេទពិតប្រាកដដែលមានចែងក្រោមវាក្យខណ្ឌរង១ (ខ) ឬ (ង) នៃមាត្រា ១៦ ឬក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចគឺវាក្យខណ្ឌរង២ (ខ) ឬ (ច) នៃមាត្រា១៦ ត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីបញ្ហានេះ។ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវផ្តល់ព័ត៌មានជូនគណៈកម្មាធិការមិនឱ្យហួសរយៈពេល១២០ ថ្ងៃ មុនកាលបរិច្ឆេទផុតកំណត់នៃការអនុវត្ត។ សមាជិកជាប្រទេសអភិវឌ្ឍតិចតួច ត្រូវផ្តល់ព័ត៌មានជូនគណៈកម្មាធិការមិនឱ្យហួសរយៈពេល ៩០ ថ្ងៃ មុនកាលបរិច្ឆេទកំណត់នោះ។

(ខ) ការជូនដំណឹងទៅគណៈកម្មាធិការ ត្រូវបង្ហាញអំពីកាលបរិច្ឆេទថ្មីដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច រំពឹងថានឹងអាចអនុវត្តបញ្ញត្តិពាក់ព័ន្ធបាន។ ការផ្តល់ព័ត៌មាននេះត្រូវបង្ហាញផងដែរអំពីមូលហេតុនៃការពន្យារពេលក្នុងការអនុវត្តដែលអាចកើតមាន។ មូលហេតុទាំងនេះអាចរួមមាន តម្រូវការសម្រាប់ជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាពដែលមិនបានរំពឹងទុកពីមុន ឬស្នើសុំជំនួយ និងការគាំទ្របន្ថែមដើម្បីជួយកសាងសមត្ថភាព។

**២.** នៅពេលដែលការស្នើសុំពេលវេលាបន្ថែមរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍មានរយៈពេលមិនលើសពី ១៨ខែ ឬក្នុងករណីការស្នើសុំពេលវេលាបន្ថែមរបស់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចមានរយៈពេលមិនលើសបីឆ្នាំ សមាជិកដាក់សំណើមានសិទ្ធិទទួលបានរយៈពេលការស្នើសុំពន្យារនោះដោយពុំចាំបាច់មានវិធានការបន្តដោយគណៈកម្មាការឡើយ។

**៣.** ក្នុងករណីសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចគិតថាខ្លួនត្រូវការពន្យារ

ពេលអនុវត្តជាលើកដំបូង លើសអំឡុងពេលដែលផ្តល់ជូនដោយវាក្យខណ្ឌទី២ ឬ ត្រូវការពន្យារពេលជាលើកទីពីរ ឬការពន្យារពេលជាបន្តបន្ទាប់ទៀត សមាជិកនោះត្រូវដាក់ពាក្យស្នើសុំជូនគណៈកម្មាធិការដើម្បីសុំពន្យារពេលដោយត្រូវផ្តល់ព័ត៌មានទាំងឡាយដែលបានបរិយាយនៅក្នុងវាក្យខណ្ឌរង១(ខ) មិនឱ្យហួសរយៈពេល ១២០ ថ្ងៃសម្រាប់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និង៩០ថ្ងៃសម្រាប់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ឱ្យបានមុនកាលកំណត់សម្រាប់ការអនុវត្តដើមដំបូង ឬកាលបរិច្ឆេទផុតកំណត់នៃការពន្យារពេលជាបន្តបន្ទាប់។

**៤.** គណៈកម្មាធិការត្រូវពិចារណាប្រកបដោយសមានចិត្ត ក្នុងការផ្តល់ឯកភាពលើសំណើសុំពន្យារពេល ដោយគិតគូរលើកាលៈទេសៈជាក់លាក់របស់សមាជិកដែលដាក់ពាក្យស្នើសុំ។ កាលៈទេសៈទាំងអស់នេះ អាចរួមមានការលំបាក និងការយឺតយ៉ាវក្នុងការទទួលជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាពជាដើម។

## មាត្រា ១៨÷ ការអនុវត្តបញ្ញត្តិប្រភេទ B និងប្រភេទ C

**១.** យោងតាមវាក្យខណ្ឌទី២ នៃមាត្រា១៣ ប្រសិនបើសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលបានអនុវត្តពេញលេញតាមនីតិវិធីចែងក្នុងវាក្យខណ្ឌទី១ ឬទី២ នៃមាត្រា១៦ និងមាត្រា១៧ និងក្នុងករណីការស្នើសុំពន្យារពេលមិនត្រូវបានអនុញ្ញាត ឬក្នុងករណីដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចជួបប្រទះផលវិបាកហួសពីការរំពឹងទុក ដែលរារាំងមិនឱ្យមានការអនុញ្ញាតចំពោះការស្នើសុំពន្យារពេលផ្អែកតាមមាត្រា១៧ ហើយវាយតម្លៃខ្លួនឯងថាសមត្ថភាពក្នុងការអនុវត្តបញ្ញត្តិប្រភេទ C នៅបន្តខ្វះខាត សមាជិកនោះត្រូវផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីការមិនមានលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តបញ្ញត្តិពាក់ព័ន្ធនោះ។

**២.** គណៈកម្មាធិការ ត្រូវបង្កើតក្រុមអ្នកជំនាញការភ្លាមៗ ហើយក្នុងករណីណាក៏ដោយមិនត្រូវឱ្យហួស៦០ ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការទទួលបាននូវព័ត៌មានពីសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឬសមាជិកប្រទេសអភិវឌ្ឍន៍តិចតួចដែលពាក់ព័ន្ធ។ ក្រុមអ្នកជំនាញការនឹងពិនិត្យមើលបញ្ហានោះ និងផ្តល់អនុសាសន៍ជូនគណៈកម្មាធិការវិញក្នុងអំឡុងពេល ១២០ ថ្ងៃ នៃការបង្កើតក្រុមអ្នកជំនាញការនោះ។

**៣.** ក្រុមអ្នកជំនាញការ ត្រូវមានសមាសភាពជាបុគ្គលឯករាជ្យចំនួនប្រាំរូប ដែលមានសមត្ថភាពក្នុងការងារកិច្ចសម្រួលពាណិជ្ជកម្ម និងការងារផ្តល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព។ សមាសភាពនៃក្រុមអ្នកជំនាញការ ត្រូវធានាបាននូវតុល្យភាពរវាងជនជាតិមកពីសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍និងជនជាតិមកពីប្រទេសអភិវឌ្ឍន៍។ ក្នុងករណីមានការពាក់ព័ន្ធជាមួយសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ក្រុមអ្នកជំនាញការត្រូវមានយ៉ាងហោចណាស់សមាសភាពម្នាក់ពីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច។ ប្រសិនបើគណៈកម្មាធិការមិនអាចយល់ព្រមលើសមាសភាពនៃក្រុមអ្នកជំនាញការនេះក្នុងរយៈពេល២០ថ្ងៃ នៃការបង្កើតវាឡើង អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ដោយមានការពិភាក្សាជាមួយប្រធាននៃគណៈកម្មាធិការ ត្រូវកំណត់សមាសភាពនៃក្រុមអ្នកជំនាញការដោយផ្អែកតាមលក្ខខណ្ឌនានានៃវាក្យខណ្ឌនេះ។

៤. ក្រុមអ្នកជំនាញការ ត្រូវពិចារណាលើការវាយតម្លៃខ្លួនឯងរបស់សមាជិកអំពីកង្វះសមត្ថភាព និងត្រូវផ្តល់អនុសាសន៍ចំពោះគណៈកម្មាធិការ។ នៅពេលពិចារណាលើអនុសាសន៍របស់ក្រុមអ្នកជំនាញការទាក់ទងនឹងសមាជិកជាប្រទេសអភិវឌ្ឍតិចតួច គណៈកម្មាធិការត្រូវចាត់វិធានការសមស្របនានាដែលនឹងជួយសម្រួលឱ្យទទួលបាននូវសមត្ថភាពក្នុងការអនុវត្តប្រកបដោយនិរន្តរភាព។

៥. ប្រទេសសមាជិក នឹងមិនស្ថិតជាកម្មវត្ថុនៃបណ្តឹងនៅក្រោមការយល់ដឹងអំពីដំណោះស្រាយវិវាទលើបញ្ហានេះឡើយ គិតចាប់ពីពេលដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍បានផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីការមិនមានលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តបញ្ញត្តិពាក់ព័ន្ធ រហូតដល់កិច្ចប្រជុំគណៈកម្មាធិការលើកដំបូងក្រោយពេលទទួលបានអនុសាសន៍ពីក្រុមអ្នកជំនាញការ។ នៅក្នុងកិច្ចប្រជុំនោះ គណៈកម្មាធិការត្រូវពិចារណាលើអនុសាសន៍របស់ក្រុមអ្នកជំនាញការ។ ចំពោះសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច បណ្តឹងនៃការយល់ដឹងអំពីដំណោះស្រាយវិវាទ មិនត្រូវបានអនុវត្តចំពោះបញ្ញត្តិពាក់ព័ន្ធ គិតចាប់ពីកាលបរិច្ឆេទនៃការផ្តល់ព័ត៌មានដល់គណៈកម្មាធិការអំពីការមិនមានលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តបញ្ញត្តិរហូតដល់ពេលដែលគណៈកម្មាធិការធ្វើសេចក្តីសម្រេចអំពីបញ្ហានោះ ឬ នៅក្នុងអំឡុងពេល ២៤ ខែ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំគណៈកម្មាធិការលើកដំបូង ដូចមានចែងខាងលើ ដោយជ្រើសយកមួយណាដែលមកដល់មុន។

៦. ក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចបាត់បង់លទ្ធភាពក្នុងការអនុវត្តការសន្យាប្រភេទ C សមាជិកនោះ អាចផ្តល់ព័ត៌មានទៅគណៈកម្មាធិការដោយត្រូវអនុវត្តតាមនីតិវិធីដូចមានចែងនៅក្នុងមាត្រានេះ។

## មាត្រា ១៩ ៖ ការផ្លាស់ប្តូររវាងបញ្ញត្តិប្រភេទ B និងបញ្ញត្តិប្រភេទ C

១. សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលបានជូនដំណឹងអំពីបញ្ញត្តិស្ថិតក្រោមប្រភេទ B និងប្រភេទ C អាចផ្លាស់ប្តូរប្រភេទនៃបញ្ញត្តិទាំងពីរតាមរយៈការជូនដំណឹងទៅគណៈកម្មាធិការ។ ក្នុងករណីដែលសមាជិកស្នើសុំផ្លាស់ប្តូរបញ្ញត្តិពីប្រភេទB ទៅជាប្រភេទC សមាជិកត្រូវផ្តល់ព័ត៌មានស្តីពីជំនួយនិងការគាំទ្រដែលត្រូវការសម្រាប់ការកសាងសមត្ថភាព។

២. ក្នុងករណីដែលតម្រូវឱ្យមានពេលវេលាបន្ថែមសម្រាប់អនុវត្តបញ្ញត្តិដែលផ្លាស់ប្តូរពី B ទៅប្រភេទ C សមាជិកអាច៖

(ក) ប្រើប្រាស់បញ្ញត្តិនានានៃមាត្រា ១៧ រួមមាន ឱកាសសម្រាប់ការពន្យារពេលដោយស្វ័យប្រវត្ត ឬ

(ខ) ស្នើសុំឱ្យមានការត្រួតពិនិត្យពីគណៈកម្មាធិការលើសំណើសុំពេលវេលាបន្ថែមរបស់សមាជិកក្នុងការអនុវត្តបញ្ញត្តិ និងប្រសិនបើចាំបាច់ ស្នើសុំជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាពរួមទាំងលទ្ធភាពនៃការស្នើសុំឱ្យមានការត្រួតពិនិត្យឡើងវិញនិងការផ្តល់អនុសាសន៍ដោយក្រុមអ្នកជំនាញការដូចមានចែងក្នុងមាត្រា ១៨ ឬ

(គ) ក្នុងករណីសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច រាល់កាលបរិច្ឆេទថ្មីសម្រាប់ការអនុវត្តដែលមានរយៈពេលលើសពីបួនឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដើមដែលបានជូនដំណឹងក្នុងប្រភេទ B ត្រូវតម្រូវឱ្យមាន

ការអនុម័តពីគណៈកម្មាធិការ។ លើសពីនេះ សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច អាចបន្តប្រើប្រាស់មាត្រា១៧។ យើងត្រូវយល់ឃើញថា សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចត្រូវការចាំបាច់នូវជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាពដើម្បីផ្លាស់ប្តូរប្រភេទនៃបញ្ញត្តិ។

## មាត្រា ២០÷ រយៈពេលអនុគ្រោះសម្រាប់ការអនុវត្ត នូវការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទ

**១.** សម្រាប់រយៈពេលពីរឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន បញ្ញត្តិនានាក្នុងមាត្រា ២២ និង ២៣ នៃកិច្ចព្រមព្រៀងGATT ១៩៩៤ ដូចបានពន្យល់និងអនុវត្តដោយការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទ មិនត្រូវយកទៅប្រើប្រាស់ដើម្បីដោះស្រាយវិវាទជាមួយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ចំពោះរាល់បញ្ញត្តិទាំងឡាយ ដែលសមាជិកនោះបានកំណត់នៅក្នុងប្រភេទ A ឡើយ។

**២.** សម្រាប់រយៈពេលប្រាំមួយឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន បញ្ញត្តិនានាក្នុងមាត្រា ២២ និង២៣ នៃកិច្ចព្រមព្រៀង GATT ១៩៩៤ ដូចបានពន្យល់និងអនុវត្តដោយការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទ មិនត្រូវយកទៅប្រើប្រាស់ដើម្បីដោះស្រាយវិវាទជាមួយសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចចំពោះរាល់បទបញ្ញត្តិទាំងឡាយ ដែលសមាជិកនោះបានកំណត់នៅក្នុងប្រភេទ A ឡើយ។

**៣.** សម្រាប់រយៈពេលប្រាំបីឆ្នាំ បន្ទាប់ពីការអនុវត្តបញ្ញត្តិនៅក្នុងប្រភេទ B ឬប្រភេទ C ដោយសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច បញ្ញត្តិនានាក្នុងមាត្រា ២២ និង២៣ នៃកិច្ចព្រមព្រៀងGATT ១៩៩៤ ដូចបានពន្យល់និងអនុវត្តដោយការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទ មិនត្រូវយកទៅប្រើប្រាស់ដើម្បីដោះស្រាយវិវាទជាមួយសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចពាក់ព័ន្ធនឹងបញ្ញត្តិទាំងនោះឡើយ។

**៤.** ដោយមិនជាប់ពាក់ព័ន្ធនឹងរយៈពេលអនុគ្រោះសម្រាប់ការអនុវត្តនូវការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទ នៅមុនពេលធ្វើការស្នើសុំពិគ្រោះយោបល់ ផ្អែកតាមមាត្រា ២២ និង ២៣ នៃកិច្ចព្រមព្រៀង GATT ១៩៩៤ នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីដោះស្រាយវិវាទពាក់ព័ន្ធនឹងវិធានការរបស់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច សមាជិកត្រូវផ្តល់ការពិចារណាលើស្ថានភាពពិសេសរបស់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច។ ក្នុងន័យនេះ សមាជិកត្រូវប្រើប្រាស់ភាពរឹតត្បឹតសមរម្យក្នុងការលើកឡើងនូវបញ្ហានានា នៅក្រោមការយល់ដឹងអំពីវិធាននិងនីតិវិធីគ្រប់គ្រងដំណោះស្រាយវិវាទដែលពាក់ព័ន្ធជាមួយសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច។

**៥.** នៅក្នុងរយៈពេលអនុគ្រោះដែលត្រូវបានអនុញ្ញាតនៅក្រោមមាត្រានេះ ប្រសិនបើមានការស្នើសុំ សមាជិកនីមួយៗត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់សមាជិកដទៃទៀតសម្រាប់ពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា ២១÷ ការផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព

១. សមាជិកជាប្រទេសផ្ដល់ជំនួយ យល់ព្រមជួយសម្រួលដល់ការផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាពដល់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចលើលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាទៅវិញទៅមកក្នុងលក្ខណៈទ្វេភាគី ឬតាមរយៈស្ថាប័នអន្តរជាតិសមស្រប។ គោលបំណងគឺដើម្បីជួយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចក្នុងការអនុវត្តបទប្បញ្ញត្តិនានាផ្នែកទី១ របស់កិច្ចព្រមព្រៀងនេះ។

២. ដោយសារមានតម្រូវការពិសេសរបស់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដូច្នេះទិសដៅនៃការផ្ដល់ជំនួយនិងការគាំទ្រត្រូវសំដៅដល់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីជួយពួកគេក្នុងការកសាងសមត្ថភាពប្រកបដោយនិរន្តរភាពសម្រាប់អនុវត្តការសន្យារបស់ពួកគេ។ តាមរយៈយន្តការសហប្រតិបត្តិការអភិវឌ្ឍន៍នានា និងស្របតាមគោលការណ៍នៃការផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ដូចមានចែងក្នុងវាក្យខណ្ឌ៣ ដៃគូអភិវឌ្ឍន៍ត្រូវខិតខំក្នុងការផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាពក្នុងវិស័យនេះ ក្នុងលក្ខខណ្ឌមួយដែលមិនជាន់គ្នាជាមួយនឹងអាទិភាពអភិវឌ្ឍន៍ដែលមានស្រាប់។

៣. សមាជិកត្រូវខិតខំអនុវត្តគោលការណ៍ដូចខាងក្រោម សម្រាប់ការផ្ដល់ជំនួយនិងការគាំទ្រដល់ការកសាងសមត្ថភាពកក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ÷

(ក) ពិចារណាលើក្របខណ្ឌអភិវឌ្ឍន៍ទូទៅរបស់បណ្ដាប្រទេសនិងតំបន់ដែលទទួលជំនួយ និងប្រសិនបើមានត្រូវពិចារណាលើកម្មវិធីកំណែទម្រង់ និងជំនួយបច្ចេកទេសដែលកំពុងអនុវត្តផងដែរ។

(ខ) ប្រសិនបើមានការពាក់ព័ន្ធនិងសមស្រប ត្រូវបញ្ចូលសកម្មភាពនានាដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ និងអនុតំបន់ និងលើកកម្ពស់សមាហរណកម្មតំបន់ និងអនុតំបន់។

(គ) ធានាបានថា សកម្មភាពកំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មនៃវិស័យឯកជនដែលកំពុងអនុវត្ត ត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពផ្ដល់ជំនួយ។

(ឃ) លើកកម្ពស់ការសម្របសម្រួលរវាងនិងក្នុងចំណោមសមាជិក និងស្ថាប័នពាក់ព័ន្ធដទៃទៀតដូចជាសហគមន៍សេដ្ឋកិច្ចក្នុងតំបន់ជាដើម ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់បំផុតនិងលទ្ធផលប្រសើរបំផុតនៃការផ្ដល់ជំនួយនេះ។ ដើម្បីសម្រេចបានដូចនេះ÷

(i) នៅក្នុងប្រទេស ឬតំបន់ដែលត្រូវទទួលជំនួយ ត្រូវមានការសម្របសម្រួលរវាងសមាជិកជាដៃគូ និងអ្នកផ្ដល់ជំនួយ និងនៅក្នុងចំណោមអ្នកផ្ដល់ជំនួយទ្វេភាគី និងពហុភាគី ដោយមានទិសដៅចៀសវាងនូវការផ្ដល់ជំនួយជាន់គ្នានិងទ្វេដង និងចៀសវាងនូវអសង្គតិភាពនៅក្នុងសកម្មភាពកំណែទម្រង់តាមរយៈការសម្របសម្រួលប្រកបដោយភាពជិតស្និទ្ធនៃអន្តរាគមន៍ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព។

(ii) សម្រាប់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ក្របខណ្ឌសមាហរណកម្មថ្មី សម្រាប់ជំនួយពាក់ព័ន្ធនឹងពាណិជ្ជកម្មសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវជាផ្នែកមួយនៃអភិក្រមសម្របសម្រួលនេះ និង

(iii) សមាជិកក៏ត្រូវលើកកម្ពស់ផងដែរនូវការសម្របសម្រួលផ្ទៃក្នុងរវាងមន្ត្រីពាណិជ្ជកម្មនិងមន្ត្រីអភិវឌ្ឍន៍ ទាំងអ្នកនៅក្នុងរាជធានីនិងអ្នកនៅក្នុងទីក្រុងហ្សឺណែវ នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ និងការងារជំនួយបច្ចេកទេស។

(ង) លើកទឹកចិត្តឱ្យប្រើប្រាស់នូវរចនាសម្ព័ន្ធសម្របសម្រួលក្នុងប្រទេស និងតំបន់ ដែលមានស្រាប់ ដូចជាកិច្ចប្រជុំតុមូល និងក្រុមពិគ្រោះយោបល់ ដើម្បីសម្របសម្រួលនិងតាមដានសកម្មភាពអនុវត្ត និង

(ច) លើកទឹកចិត្តសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យផ្តល់ការកសាងសមត្ថភាពដល់សមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចដទៃទៀត និងពិចារណាផ្តល់ការគាំទ្រចំពោះសកម្មភាពបែបនោះ ប្រសិនបើមានលទ្ធភាព។

៤. គណៈកម្មាធិការត្រូវបើកសម័យប្រជុំយ៉ាងតិចម្តងក្នុងមួយឆ្នាំ ដើម្បី៖

(ក) ពិភាក្សារាល់បញ្ហាទាក់ទងនឹងការអនុវត្តបញ្ញត្តិ ឬអនុផ្នែកនៃបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ។

(ខ) ត្រួតពិនិត្យវឌ្ឍនភាពក្នុងការផ្តល់ជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវបញ្ហាដែលសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលមិនបានទទួលជំនួយនិងការគាំទ្រគ្រប់គ្រាន់សម្រាប់ការកសាងសមត្ថភាពផងដែរ។

(គ) ចែករំលែកបទពិសោធន៍និងព័ត៌មានស្តីពីការផ្តល់ជំនួយនិងការគាំទ្រដែលកំពុងអនុវត្តសម្រាប់ការកសាងសមត្ថភាព និងកម្មវិធីអនុវត្ត រួមមានបញ្ហាប្រឈម និងជោគជ័យ។

(ឃ) ត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ប្រទេសផ្តល់ជំនួយ ដូចមានចែងក្នុងមាត្រា២២ និង

(ង) ត្រួតពិនិត្យការប្រតិបត្តិវាក្យខណ្ឌទី២។

## មាត្រា ២២៖ ព័ត៌មានស្តីពីជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ដែលត្រូវដាក់ជូនគណៈកម្មាធិការ

**១.** ដើម្បីផ្តល់តម្លាភាពដល់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចស្តីពីការផ្តល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាពក្នុងការអនុវត្តន៍ផ្នែកទី១ សមាជិកជាប្រទេសផ្តល់ជំនួយនីមួយៗ ដែលជួយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចអនុវត្តនូវកិច្ចព្រមព្រៀងនេះ ត្រូវដាក់ជូនគណៈកម្មាធិការ នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងបន្ទាប់ពីនេះត្រូវធ្វើឡើងជារៀងរាល់ឆ្នាំនូវព័ត៌មានដូចខាងក្រោមស្តីពីការផ្តល់ជំនួយ និងការគាំទ្ររបស់ខ្លួនសម្រាប់ការកសាងសមត្ថភាព ដែលបានចំណាយក្នុងរយៈពេល១២ខែ និងប្រសិនបើអាចព័ត៌មានអំពីចំណាយដែលត្រូវធ្វើក្នុងរយៈពេល១២ខែបន្ទាប់[២២]៖

[២២] ព័ត៌មានដែលបានផ្តល់ជូននឹងឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈនៃការផ្តល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាពផ្អែកតាមតម្រូវការ។

(ក) សេចក្ដីបរិយាយអំពីការផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព

(ខ) ស្ថានភាពនិងចំនួនទឹកប្រាក់ដែលបានសន្យា/បានចំណាយ

(គ) នីតិវិធីសម្រាប់ការចំណាយសម្រាប់ការផ្ដល់ជំនួយ និងការគាំទ្រ

(ឃ) សមាជិកដែលទទួលផល ឬប្រសិនបើចាំបាច់ តំបន់ដែលទទួលផល និង

(ង) ទីភ្នាក់ងារអនុវត្តនៅក្នុងប្រទេសជាសមាជិកដែលផ្ដល់ជំនួយនិងការគាំទ្រ

ព័ត៌មានទាំងនោះ ត្រូវផ្ដល់ក្នុងទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធ១។ ក្នុងករណីអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (ហៅកាត់ថា “OECD”) ព័ត៌មានដែលត្រូវដាក់ជូនគណៈកម្មាធិការអាចផ្អែកលើព័ត៌មានដែលមាននៅក្នុងប្រព័ន្ធរាយការណ៍ឥណទានិកររបស់ OECD។ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រកាសថា ចង់ផ្ដល់ជំនួយនិងការគាំទ្រសម្រាប់ការកសាងសមត្ថភាព ត្រូវបានលើកទឹកចិត្តឱ្យផ្ដល់ព័ត៌មានខាងលើ។

២. សមាជិកជាប្រទេសផ្ដល់ជំនួយដែលជួយសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ត្រូវដាក់ជូនគណៈកម្មាធិការនូវព័ត៌មានដូចខាងក្រោម÷

(ក) ចំណុចទំនាក់ទំនងនៃទីភ្នាក់ងារទទួលខុសត្រូវលើការផ្ដល់ជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាពពាក់ព័ន្ធនឹងការអនុវត្តន៍ផ្នែកទី១នៃកិច្ចព្រមព្រៀងនេះ រួមមាន ព័ត៌មានស្ដីពីចំណុចទំនាក់ទំនងនៅក្នុងប្រទេស ឬតំបន់ ជាទីកន្លែងដែលត្រូវផ្ដល់ជំនួយ និងការគាំទ្រ និង

(ខ) ព័ត៌មានស្ដីពីអភិក្រមនិងយន្តការសម្រាប់ស្នើសុំជំនួយ និងការគាំទ្រសម្រាប់ការកសាងសមត្ថភាព។

សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រកាសខ្លួនឯងថាចង់ផ្ដល់ជំនួយ និងការគាំទ្រត្រូវបានលើកទឹកចិត្តឱ្យផ្ដល់ព័ត៌មានដូចខាងលើ។

៣. សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលមានបំណងទទួលជំនួយនិងការគាំទ្រពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការកសាងសមត្ថភាពត្រូវដាក់ជូនគណៈកម្មាធិការនូវព័ត៌មានស្ដីពីចំណុចទំនាក់ទំនងនៃការិយាល័យដែលទទួលខុសត្រូវលើការងារសម្របសម្រួលនិងផ្ដល់អាទិភាពលើជំនួយនិងការគាំទ្រនោះ។

៤. សមាជិកអាចផ្ដល់ព័ត៌មានដែលមានចែងក្នុងវាក្យខណ្ឌទី២ និងវាក្យខណ្ឌ៣ តាមរយៈអ៊ីនធើណិត ហើយត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងនោះតាមការចាំបាច់។ លេខាធិការដ្ឋានត្រូវបង្ហាញព័ត៌មានទាំងនេះជាសាធារណៈ។

៥. គណៈកម្មាធិការត្រូវអញ្ជើញអង្គការអន្តរជាតិ និងអង្គការប្រចាំតំបន់ដែលពាក់ព័ន្ធ (ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ អង្គការសន្និសីទសហប្រជាជាតិស្ដីពីពាណិជ្ជកម្មនិងការអភិវឌ្ឍន៍ អង្គការគយពិភពលោក ស្នងការថ្នាក់តំបន់របស់សហប្រជាជាតិ ធនាគារពិភពលោក ឬស្ថាប័នជាសាខារបស់អង្គការទាំងនោះ និងធនាគារអភិវឌ្ឍន៍នៅតាមតំបន់) និងទីភ្នាក់ងារសហប្រតិបត្តិការដទៃទៀត ឱ្យផ្ដល់ព័ត៌មានដែលមានចែងនៅក្នុងវាក្យខណ្ឌទី១, ២ និង៤។

# ផ្នែកទី III

# ការរៀបចំស្ថាប័ននិងអវសានបញ្ញត្តិ

## មាត្រា ២៣÷ ការរៀបចំស្ថាប័ន

### ១. គណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម

១.១ គណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម គឺត្រូវបានបង្កើតឡើង។

១.២ គណៈកម្មាធិការត្រូវបានបើកចំហសម្រាប់ការចូលរួមពីសមាជិកទាំងអស់ និងត្រូវជ្រើសរើសប្រធានរបស់ខ្លួន។ គណៈកម្មាធិការត្រូវប្រជុំតាមការចាំបាច់ និងផ្អែកតាមបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនត្រូវតិចជាងម្តងក្នុងមួយឆ្នាំទេក្នុងគោលបំណងផ្តល់ឱកាសដល់សមាជិកដើម្បីពិគ្រោះយោបល់លើរាល់បញ្ហាដែលពាក់ព័ន្ធនឹងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ ឬធ្វើឱ្យប្រសើរឡើងនូវកម្មវត្ថុរបស់កិច្ចព្រមព្រៀងនេះ ឬដែលត្រូវបានប្រគល់ជូនដោយសមាជិក។ គណៈកម្មាធិការត្រូវបង្កើតវិធាននៃនីតិវិធីរបស់ខ្លួន។

១.៣ គណៈកម្មាធិការអាចបង្កើតស្ថាប័នចំណុះរបស់ខ្លួនទៅតាមតម្រូវការ។ ស្ថាប័នទាំងនោះ ត្រូវរាយការណ៍ជូនគណៈកម្មាធិការ។

១.៤ គណៈកម្មាធិការត្រូវបង្កើតនីតិវិធីសម្រាប់ឱ្យសមាជិកធ្វើការចែករំលែកនូវព័ត៌មានពាក់ព័ន្ធ និងការអនុវត្តល្អបំផុត តាមការសមស្រប។

១.៥ គណៈកម្មាធិការ ត្រូវរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយអង្គការអន្តរជាតិដទៃទៀតក្នុងវិស័យកិច្ចសម្រួលពាណិជ្ជកម្ម ដូចជា អង្គការគយពិភពលោក ជាដើម ក្នុងគោលបំណងធានាបាននូវការផ្តល់ដំបូន្មានប្រសើរបំផុតដែលអាចរកបានសម្រាប់ការអនុវត្ត និងការគ្រប់គ្រងកិច្ចព្រមព្រៀងនេះ និងដើម្បីធានាថាការប្រឹងប្រែងដូចគ្នាដែលមិនចាំបាច់ ត្រូវបានចៀសវាង។ ដើម្បីសម្រេចបំណងនេះ គណៈកម្មាធិការអាចអញ្ជើញតំណាងអង្គការទាំងនេះ ឬស្ថាប័នចំណុះ÷

(ក) ចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការ និង

(ខ) ពិភាក្សាអំពីបញ្ហាជាក់លាក់នានាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ និងត្រូវពិនិត្យមើលជារៀងរាល់ឆ្នាំបន្ទាប់ពីនេះ។

១.៦ គណៈកម្មាធិការ ត្រូវត្រួតពិនិត្យមើលនូវប្រតិបត្តិការនៃការអនុវត្តកិច្ចព្រមព្រៀងនេះក្នុងរយៈពេល៤ឆ្នាំ ក្រោយពេលចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងត្រូវពិនិត្យមើលជារៀងរាល់ឆ្នាំបន្ទាប់ពីនោះ។

១.៧ សមាជិកទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យលើកសំណួរទៅគណៈកម្មាធិការអំពីបញ្ហានៃការអនុវត្តនិងការប្រើប្រាស់កិច្ចព្រមព្រៀងនេះ។

១.៨ គណៈកម្មាធិការ ត្រូវលើកទឹកចិត្តនិងសម្រួលឱ្យមានកិច្ចពិភាក្សាអាដហុកក្នុងចំណោមសមាជិកអំពីបញ្ហាជាក់លាក់នានាក្នុងកិច្ចព្រមព្រៀងនេះ ដើម្បីទទួលបានភ្លាមៗនូវដំណោះស្រាយដែលមានការពេញចិត្តទាំងអស់គ្នា។

**២. គណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម**

សមាជិកនីមួយៗត្រូវបង្កើត និង/ ឬរក្សាទុកនូវគណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម ឬចាត់តាំងយន្តការដែលមានស្រាប់ ដើម្បីជួយសម្រួលដល់ការងារសម្របសម្រួលក្នុងស្រុកផង និងអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះផង។

## មាត្រា ២៤÷ អវសានបញ្ញត្តិ

**១.** សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យ "សមាជិក" ត្រូវចាត់ទុកថា រាប់បញ្ចូលទាំងអាជ្ញាធរមានសមត្ថកិច្ចរបស់សមាជិកនោះផង។

**២.** បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ ចងកាតព្វកិច្ចលើសមាជិកទាំងអស់។

**៣.** សមាជិកត្រូវអនុវត្តកិច្ចព្រមព្រៀងនេះ គិតចាប់ពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលជ្រើសរើសប្រើប្រាស់បញ្ញត្តិនានានៃផ្នែកទី២ ត្រូវអនុវត្តកិច្ចព្រមព្រៀងនេះអនុលោមតាមផ្នែកទី២។

**៤.** សមាជិកដែលទទួលយកកិច្ចព្រមព្រៀងនេះ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមានត្រូវអនុវត្តការសន្យាប្រភេទ B និងប្រភេទ C ដោយគណនារយៈពេលពាក់ព័ន្ធ ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

**៥.** សមាជិកនៃសហភាពគយ ឬសមាជិកនៃសហគមន៍សេដ្ឋកិច្ចតំបន់ អាចប្រើប្រាស់យន្តការតំបន់ដើម្បីជួយសម្រួលដល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀងនេះដូចជា តាមរយៈការបង្កើតនិងប្រើប្រាស់ស្ថាប័នតំបន់ជាដើម។

**៦.** ដោយមិនជាប់ពាក់ព័ន្ធនឹងកំណត់សម្គាល់នៃការបកស្រាយទូទៅចំពោះឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលត្រូវចាត់ទុកបានកាត់បន្ថយកាតព្វកិច្ចរបស់សមាជិក នៅក្រោមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យនិងភូតគាមអនាម័យឡើយ។

**៧.** រាល់ការលើកលែង និងការអនុគ្រោះទាំងឡាយ[២៣] នៅក្រោមកិច្ចព្រមព្រៀង GATT ១៩៩៤។ បន្ថែមពីលើនេះ គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ។ ការលើកលែងដែលប្រើប្រាស់នៅក្នុង GATT ១៩៩៤ ឬផ្នែកណាមួយនៃការលើកលែងនោះ ដែលត្រូវបានផ្តល់ក្រោមមាត្រា ៩: ៣ និងមាត្រា ៩: ៤ នៃកិច្ចព្រមព្រៀង

---

[២៣] ការលើកលែងនេះ រួមបញ្ចូលនូវមាត្រា ៥: ៧ និងមាត្រា ១០:១ នៃកិច្ចព្រមព្រៀង GATT ១៩៩៤ និងកំណត់សម្គាល់នៃមាត្រា៨ នៃ GATT ១៩៩៤។

ម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងវិសោធនកម្មនានាដែលបានធ្វើឡើងនៅខណៈដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន នឹងត្រូវយកមកអនុវត្តចំពោះបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះដែរ។

**៨.** បញ្ញត្តិនានានៃមាត្រា២២ និងមាត្រា២៣ នៃកិច្ចព្រមព្រៀង GATT ១៩៩៤ ដូចបានបរិយាយ និងបានអនុវត្តដោយការយល់ដឹងអំពីដំណោះស្រាយវិវាទ ត្រូវអនុវត្តចំពោះការពិគ្រោះយោបល់ និងការដោះស្រាយវិវាទនៅក្រោមកិច្ចព្រមព្រៀងនេះ លើកលែងតែមានការចែងផ្សេងពីនេះ នៅក្នុងកិច្ចព្រមព្រៀងនេះ។

**៩.** ការបម្រុងទុកផ្សេងៗ អាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ដោយគ្មានការយល់ព្រមពីសមាជិកផ្សេងទៀតឡើយ។

**១០.** ការសន្យាប្រភេទ A របស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួចដែលបានភ្ជាប់ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ យោងតាមវាក្យខណ្ឌ១ និង២ នៃមាត្រា១៥ នឹងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

**១១.** ការសន្យាប្រភេទ B និងប្រភេទ C របស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ដែលត្រូវបានកត់ត្រាដោយគណៈកម្មាធិការ និងត្រូវបានដាក់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ យោងតាមវាក្យខណ្ឌ៥ នៃមាត្រា១៦ នឹងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## ឧបសម្ព័ន្ធ ១÷ ទម្រង់សម្រាប់ការផ្ដល់ព័ត៌មានក្រោមវាក្យខណ្ឌ១ នៃមាត្រា ២២

សមាជិកជាអ្នកផ្ដល់ជំនួយ÷

រយៈពេលនៃការផ្ដល់សេចក្ដីជូនដំណឹង÷

| | | | | | |
|---|---|---|---|---|---|
| | បរិយាយអំពីជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុនិងធនធានសម្រាប់ការកសាងសមត្ថភាព | ស្ថានភាព និងទឹកប្រាក់ដែលបានសន្យា/ចំណាយ | ប្រទេស/តំបន់ (ប្រសិនបើចាំបាច់) ដែលទទួលផល | ទីភ្នាក់ងារអនុវត្តនៅក្នុងប្រទេសដែលផ្ដល់ជំនួយ | នីតិវិធីសម្រាប់ចំណាយក្នុងការផ្ដល់ជំនួយ |